**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| **ដាក់ទៅ** | : | អង្គជំនុំជម្រះតុលាការកំពូល |
| **ថ្ងៃដាក់** | : | ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញា |
| **ភាសាដើម** | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 20-Aug-2019, 13:44
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ:** **សាធារណៈ**

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល:** សាធារណៈ/Public

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**

**ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**

**ហត្ថលេខា:**

---

**បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿងលេខ ០០២/០២**

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោកស្រី Brenda J. HOLLIS (បម្រុង)

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះតុលាការកំពូល:**
ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម C.N. JAYASINGHE
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Florence Ndepele MUMBA
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Maureen HARDING CLARK
ចៅក្រម យ៉ា ណារិន

**ចម្លងជូន:**

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
លោក ពេជ អង្គ

**ជនជាប់ចោទ:**
ខៀវ សំផន

**មេធាវីការពារក្តី ខៀវ សំផន:**
លោក គង់ សំអុន
លោកស្រី Anta GUISSÉ

# I. សេចក្តីផ្តើម

1. នៅក្នុងសាលក្រមសំណុំរឿង ០០២/០២ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងៗទៀត ត្រូវបានប្រព្រឹត្តតាមរយៈអំពើដែលត្រូវបានកំណត់ថាជាអំពើរំលោភសេពសន្ថវៈក្នុងបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ"[1]។ ទោះជាយ៉ាងណាថ្វីបើមិនបានបញ្ជាក់ត្រង់ចំណុចនេះឱ្យបានច្បាស់លាស់ដូច្នេះក្តី ក៏ការសម្រេចនេះអនុវត្តចំពោះតែស្ត្រីប៉ុណ្ណោះ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា *បុរស* ដែលត្រូវបានបង្ខំឱ្យរួមដំណេកនៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំរបស់ពួកគេ *មិនមែន* ជាជនរងគ្រោះនៃអំពើរំលោភសេពសន្ថវៈទេ ដោយសារនិយមន័យនៃអំពើរំលោភសេពសន្ថវៈដែលមានអត្ថិភាពក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[2]។ បន្ទាប់មក អង្គជំនុំជម្រះក៏បានពិចារណាថាតើ អំពើនោះមានគុណវុឌ្ឍិជាអំពើហិង្សាផ្លូវភេទដែលក្នុងស្ថានទម្ងន់ដូច្នេះ មានតម្លៃស្មើនឹងអំពើអមនុស្សធម៌ផ្សេងៗទៀតដែរឬទេ[3]។ ការវិភាគនោះដែលមាននៅក្នុងកថាខណ្ឌតែមួយគត់នៃសាលក្រម បានទទួលស្គាល់ថា បុរសដែលត្រូវបានបង្ខំឱ្យរួមដំណេកក្នុងអាពាហ៍អាពាហ៍ដោយបង្ខំរបស់ពួកគេ បានទទួលរងអំពើហិង្សាផ្លូវភេទដែល "ផ្ទុយពីសេចក្តីថ្លៃថ្នូររបស់មនុស្ស"[4]។ ក៏ប៉ុន្តែ តាមអ្វីដែលអង្គជំនុំជម្រះសាលាដំបូងបានហៅថា "គ្មានភ័ស្តុតាងច្បាស់លាស់ទាក់ទងនឹងកម្រិតនៃភាពធ្ងន់ធ្ងរនៃអំពើប្រភេទនេះ និងផលប៉ះពាល់របស់វា" នោះ អង្គជំនុំជម្រះក៏បានថ្លែងថា ខ្លួនមិនអាចរកឃើញថា អំពើនោះបង្កើតបានជាអំពើអមនុស្សធម៌ផ្សេងៗទៀតឡើយ[5]។

2. សហព្រះរាជអាជ្ញាប្តឹងសាទុក្ខចំពោះការដកចេញនូវជនរងគ្រោះដែលជាបុរស ដោយសារការរួមដំណេកដោយបង្ខំនេះចេញពីការផ្តន្ទាទោសនៃអំពើអមនុស្សធម៌ផ្សេងៗទៀត ក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយផ្អែកលើទឡ្ហីករណ៍សំខាន់ចំនួនពីរ[6]។ ទីមួយ អង្គជំនុំជម្រះសាលាដំបូងមានកំហុសខាងអង្គច្បាប់ ដោយខកខានមិនបានអនុវត្តច្បាប់ត្រឹមត្រូវ ស្តីពីអំពើអមនុស្សធម៌ផ្សេងៗ

---

[1] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២, ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ("សាលក្រមសំណុំរឿង ០០២/០២"), កថាខណ្ឌ ៣៧០០។

[2] សាលក្រមសំណុំរឿង ០០២/០២, កថាខណ្ឌ ៧៣១, ៣៧០១ (សង្កត់ន័យដើម)។

[3] សាលក្រមសំណុំរឿង ០០២/០២, កថាខណ្ឌ ៣៧០១។

[4] សាលក្រមសំណុំរឿង ០០២/០២, កថាខណ្ឌ ៣៧០១។

[5] សាលក្រមសំណុំរឿង ០០២/០២, កថាខណ្ឌ ៣៧០១។

[6] អនុលោមតាមវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិសោធនកម្មលើកទី៩ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ("វិធានផ្ទៃក្នុង") វិធាន ១០៤ និងវិធាន ១០៥។

ទៀត ដែលជាការសាកល្បងផ្លូវច្បាប់ ដោយមិនបានកំណត់ថាតើការបង្ខំបុគ្គលណាម្នាក់ឱ្យរួមដំណេក បង្កើតបានជាការវាយប្រហារធ្ងន់ធ្ងរទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្ស។ ទីពីរ អង្គជំនុំជម្រះមានកំហុសឆ្គងខាងអង្គច្បាប់ ដោយខកខានមិនបានរកឱ្យឃើញថា ការបង្ខំបុរសឱ្យរួមដំណេក បណ្តាលឱ្យមានការឈឺចាប់ និងព្យសនកម្មផ្លូវកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរ។ កំហុសផ្លូវច្បាប់នេះបានកើតឡើងនៅពេលដែលអង្គជំនុំជម្រះសាលាដំបូង ខកខានមិនបានផ្តល់ការយល់ឃើញប្រកបដោយសម្អាងហេតុ និងខកខានមិនបានពិចារណាភស្តុតាងពាក់ព័ន្ធ និងកំហុសអង្គហេតុដែលបានកើតឡើងនៅពេល ដែលអង្គជំនុំជម្រះសាលាដំបូងធ្វើសេចក្តីសន្និដ្ឋានមួយដោយមិនសមហេតុសមផល ដែលអង្គជំនុំជម្រះសាលាដំបូងអាចធ្វើសេចក្តីសន្និដ្ឋានដោយផ្អែកលើភស្តុតាង និងការរកឃើញរបស់ខ្លួនដោយផ្ទាល់។ កំហុសអង្គហេតុ និងកំហុសអង្គច្បាប់ បានធ្វើមោឃៈសេចក្តីសម្រេច និងបង្កើតឱ្យមានភាពអយុត្តិធម៌។

3. ជាលទ្ធផល សហព្រះរាជអាជ្ញាបានស្នើថា កំហុសនៃការរកឃើញ ត្រូវទុកមួយឡែកសិន ហើយការផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មនៃអំពើអមនុស្សធម៌ផ្សេងៗទៀត ត្រូវកែតម្រូវ ដោយបញ្ចូលហិង្សាខាងផ្លូវភេទ (លើជនរងគ្រោះជាបុរស) ដើម្បីឱ្យជនរងគ្រោះជាស្ត្រី និងបុរសដែលបានទទួលរងដោយការរួមភេទដោយបង្ខំក្នុងអំពើតែមួយនេះ ត្រូវបានទទួលស្គាល់ឱ្យបានសមស្រប។

## II. ប្រវត្តិនីតិវិធី

4. នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ អង្គជំនុំជម្រះសាលាដំបូង បានប្រកាសសាលក្រមផ្តន្ទាទោសក្នុងសំណុំរឿង ០០២/០២ របស់ខ្លួន ដោយផ្តល់សេចក្តីសង្ខេបផ្ទាល់មាត់អំពីការរកឃើញ និងផ្នែកសម្រេចសេចក្តីនៃសាលក្រម។ អង្គជំនុំជម្រះបានថ្លែងថា បញ្ជីនៃប្រភពច្បាប់យោងនៃការសម្រេចរបស់ខ្លួន នឹងអាចរកបាននៅក្នុងសាលក្រមជាលាយលក្ខណ៍អក្សរនៅក្នុងពេលវេលាសមស្រប[7]។ សាលក្រមជាលាយលក្ខណ៍អក្សរនោះ ជាភាសាខ្មែរ អង់គ្លេស និងបារាំង ត្រូវបានចេញនាពេលក្រោយមក នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩[8]។

[7] ឯកសារ **E1/529.1** ការប្រកាសសាលក្រមក្នុងសំណុំរឿង ០០២/០២, ប្រតិចារឹក, ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨, ម៉ោង 09:34:35-09:36:02។

[8] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២។

5. នៅក្នុងចម្លើយតបទៅនឹងសំណើរបស់ នួន ជា និង ខៀវ សំផន[9] អង្គជំនុំជម្រះតុលាការកំពូល ("អជតក") បានផ្តល់ជូនភាគីទាំងអស់នូវរយៈពេលបន្ថែមចំនួនពីរខែ ដើម្បីដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ដោយបង្គាប់ឲ្យដាក់សេចក្តីជូនដំណឹងនេះនៅថ្ងៃ ឬមុនថ្ងៃទី១ ខែកក្កដា ឆ្នាំ ២០១៩[10]។

6. នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ខ្លួន[11] ធ្វើឲ្យសារណាបណ្តឹងសាទុក្ខនេះដល់ថ្ងៃកំណត់នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩[12]។

## III. ច្បាប់ជាធរមាន និងសាវតារ

### ក. ភាពអាចទទួលយកបាន

7. វិធាន ១០៥(១)(ក) នៃវិធានផ្ទៃក្នុង អនុញ្ញាតឲ្យសហព្រះរាជអាជ្ញាដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។

### ខ. បទដ្ឋាននៃការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខ

8. បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង អាចត្រូវបានអនុញ្ញាតធ្វើទៅបានដោយសម្អាងលើទឡ្ហីករណ៍ចំនួនពីរ៖ "កំហុសលើអង្គច្បាប់ ដែលនាំឲ្យមោឃៈសាលក្រមលើអង្គសេចក្តី [...] កំហុសនៃអង្គហេតុ ដែលនាំឲ្យសាលក្រមលើអង្គសេចក្តី ឬ សេចក្តីសម្រេចនោះមានភាពអយុត្តិធម៌"[13]។

---

[9] ឯកសារ **F39/1.1** សំណើរបស់លោក ខៀវ សំផន សុំពន្យារពេល និងបន្ថែមចំនួនទំព័រនៃសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ, ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៩។ ឯកសារ **F40/1.1** សំណើបន្ទាន់លើទីមួយរបស់ នួន ជា សុំចំនួនទំព័រ និងពេលវេលាបន្ថែមសម្រាប់ការដាក់ជូនសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ជំទាស់ទៅនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង ០០២/០២, ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៩។

[10] ឯកសារ **F43** សេចក្តីសម្រេចលើសំណើរបស់ នួន ជា និង ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ, ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩, កថាខណ្ឌ១១, ១៣។

[11] ឯកសារ **E465/2/1** សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញា អំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២, ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩។

[12] វិធាន ១០៧(៤) នៃវិធានផ្ទៃក្នុង (ចែងថា សារណាបណ្តឹងសាទុក្ខត្រូវដាក់ក្នុងរយៈពេល៦០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងពីការប្តឹងសាទុក្ខ)។

[13] វិធានផ្ទៃក្នុង ១០៤(១)។ *កត់សម្គាល់* ថាបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចលើដំណើរការនីតិវិធី ត្រូវបានចាត់ទុកថា ឬមួយជាកំហុសលើអង្គច្បាប់ ឬមួយជាកំហុសនៃអង្គហេតុ។ *សូមអាន* ឯកសារ **F36** សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ ២០១៦ ("សាលដីកាលើសំណុំរឿង ០០២/០១") កថាខណ្ឌ ៨៦។

9. កាលណាកំហុសខាងអង្គច្បាប់ត្រូវបានលើកឡើង អ.ជ.ត.ក ត្រូវតែកំណត់ថាតើការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូងខាងអង្គច្បាប់នោះត្រឹមត្រូវដែរឬទេ មិនមែនគ្រាន់តែថាតើវា សមហេតុសមផលដែរឬទេប៉ុណ្ណោះទេ[14]។ ប្រសិនបើកំហុសនោះបានកើតឡើងពីការអនុវត្តបទដ្ឋានច្បាប់ដែលខុសឆ្គងរបស់អង្គជំនុំជម្រះសាលាដំបូង នោះ អ.ជ.ត.ក ត្រូវកំណត់ពីបទដ្ឋានច្បាប់ដែលត្រឹមត្រូវ ហើយអនុវត្តទៅលើភស្តុតាងដែលមាននៅក្នុងកំណត់ហេតុជំនុំជម្រះ ដោយកំណត់ថាតើអង្គជំនុំជម្រះខ្លួនឯងផ្ទាល់ជឿជាក់ចំពោះបទដ្ឋាននៃការបង្ហាញភស្តុតាងពាក់ព័ន្ធចំពោះសម្អាងហេតុដែលត្រូវបានជំទាស់នោះ ឬយ៉ាងណា[15]។ អ.ជ.ត.ក អាចកែប្រែសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងបាន ដរាបណាកំហុសខាងអង្គច្បាប់នោះ ធ្វើឲ្យមោឃៈសាលក្រម ឬសេចក្តីសម្រេចនោះប៉ុណ្ណោះ[16]។

10. នៅពេលកំហុសអង្គហេតុត្រូវបានចោទប្រកាន់ អជតក ត្រូវតែកំណត់ថាតើ ការសន្និដ្ឋាននោះសមហេតុផលដែរឬអត់ មិនមែនថាតើវាត្រឹមត្រូវឬអត់នោះទ[17]។ អជតក ពីមុនធ្លាប់បានយល់ស្របជាមួយនឹងអភិក្រមទូទៅរបស់តុលាការ ICTY អំពីការផ្តល់ជូននូវការយល់ស្របមួយចំណែកតូចតាមការរកឃើញផ្នែកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូង ដោយបានលើកឡើងថា ខ្លួន "នឹងមិនរំខានសូម្បីតែបន្តិច" ដល់ការសម្រេចដូច្នេះទេ[18]។ ដើម្បីបដិសេធសេចក្តីសម្រេចណាមួយរបស់អង្គជំនុំជម្រះសាលាដំបូង កំហុសអង្គហេតុត្រូវតែបង្កើតឲ្យមានភាពអយុត្តិធម៌ មានន័យថា វាត្រូវតែ "ធ្ងន់ធ្ងរដល់សាលក្រមផ្តន្ទាទោស"[19]។

## គ. យុត្តិសាស្ត្រសំណុំរឿង០០២ទាក់ទងនឹងអំពើអមនុស្សធម៌ផ្សេងៗទៀត

---

[14] ឯកសារ **F36** សាលដីកាលើសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៨ *ដោយបានលើកឡើងពី* សំណុំរឿង ០០១-ឯកសារ **F28** សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ("សាលដីកា *ឌុច*") កថាខណ្ឌ ១៤។

[15] ឯកសារ **F36** សាលដីកាលើសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៦ *ដោយបានលើកឡើងពី* សំណុំរឿង ០០១-ឯកសារ **F28** សាលដីកា *ឌុច* កថាខណ្ឌ ១៦។

[16] ឯកសារ **F36** សាលដីកាលើសំណុំរឿង ០០២/០១ កថាខណ្ឌ ៨៦ *ដោយបានលើកឡើងពី* សំណុំរឿង ០០១-ឯកសារ **F28** សាលដីកា *ឌុច* កថាខណ្ឌ ១៦។

[17] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ ៨៨ *យោង* សំណុំរឿង ០០១-ឯកសារ **F28** សាលដីកា ឌុច, កថាខណ្ឌ ១៧។

[18] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ ៨៨-៨៩ *យោង* សំណុំរឿង ០០១-ឯកសារ **F28** សាលដីកា ឌុច, កថាខណ្ឌ ១៧។

[19] សំណុំរឿង ០០១-ឯកសារ **F28** សាលដីកា ឌុច, កថាខណ្ឌ ១៩ *យោង* សាលដីកា *Kupreškić*, កថាខណ្ឌ ២៩។

11. នៅក្នុងដីកាដំណោះស្រាយនៃសំណុំរឿង ០០២ សហចៅក្រមស៊ើបអង្កេត ("ស.ច.ស") បានរកឃើញថា ការបង្ខំឱ្យរួមសង្វាសពេលរៀបការរួចក្នុងកាលៈទេសបង្ខិតបង្ខំដោយគ្មានការព្រមព្រៀងពីជនរងគ្រោះ គឺជាអំពើរំលោភសេពសន្ថវៈ[20]។ អាស្រ័យហេតុនេះ សហចៅក្រមស៊ើបអង្កេតបានចោទប្រកាន់ជនជាប់ចោទអំពីការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃអំពើរំលោភសេពសន្ថវៈ និងបានថ្លែងថា អង្គហេតុនានាអាចនឹងត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សធម៌ផ្សេងៗទៀត តាមរយៈអំពើហិង្សាផ្លូវភេទ[21]។

12. ក្នុងពេលបន្តបន្ទាប់មក ទាំងអង្គបុរេជំនុំជម្រះ ("អ.ប.ជ") និងទាំង អ.ជ.ត.ក បានសម្រេចថា នៅក្នុងកំឡុងពេលនៃយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ការរំលោភសេពសន្ថវៈ នៅមិនទាន់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដាច់ដោយឡែក នៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិទេ[22]។ យ៉ាងណាក៏ដោយ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅមុនឆ្នាំ ១៩៧៥ បានបន្សល់នូវប្រភេទមួយ ដើម្បីធ្វើឱ្យទៅជាឧក្រិដ្ឋកម្មនូវទង្វើណាដែលឈានដល់ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប៉ុន្តែមិនត្រូវទៅនឹងឧក្រិដ្ឋកម្មប្រភេទមួយណាជាក់លាក់ (ដែល

---

[20] ឯកសារ **D427** ដីកាដំណោះស្រាយ, កថាខណ្ឌ ១៤៣១។

[21] ឯកសារ **D427** ដីកាដំណោះស្រាយ, កថាខណ្ឌ ១៤៣០-១៤៣៣, ១៥២៥(v), ១៥៤៥, ១៥៤៨, ១៥៥១, ១៥៥៤, ១៦១៣។

[22] សំណុំរឿង ០០១-ឯកសារ **F28** សាលដីកា *ឌុច* កថាខណ្ឌ ១៨៣, ២១៣។ ឯកសារ **D427/2/15** សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ ("សាលដីកាប្រឆាំងនឹងដីកាដំណោះស្រាយរបស់ នួន ជា និង អៀង ធីរិទ្ធ") កថាខណ្ឌ ១៤៩-១៥៤។ ឯកសារ **D427/1/30** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ("សាលដីកាប្រឆាំងនឹងដីកាដំណោះស្រាយរបស់ អៀង សារី") កថាខណ្ឌ ៣៦៤-៣៧១។

បានវាយតាមលំដាប់) នោះទេ[23]។ ដូច្នេះ ការចោទប្រកាន់ពីការរំលោភសេពសន្ថវៈ ត្រូវបានកំណត់ថាជាបទចោទមួយនៃអំពើអមនុស្សធម៌ផ្សេងៗទៀត នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[24]។

13. អ.ជ.ត.ក បានសម្រេចថា ធាតុផ្សំដូចតទៅនេះ ត្រូវតែបានបង្ហាញសម្ចីកម្មចំពោះទង្វើដែលបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងៗទៀត៖

i) អំពើសកម្ម ឬអកម្មដែលមានភាពធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាទៅនឹងអំពើជាក់លាក់ដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមុស្សជាតិ

ii) អំពើសកម្ម ឬអកម្មដែលបណ្តាលឲ្យមានការឈឺចាប់ ឬព្យសនកម្មធ្ងន់ធ្ងរលើរូបកាយ ឬផ្លូវចិត្ត ឬជាការប៉ះពាល់ធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ និង

iii) អំពើសកម្ម ឬអកម្មដែលបានប្រព្រឹត្តឡើងដោយចេតនា[25]។

14. អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងវិញនូវតេស្តនៃធាតុផ្សំទាំងបីរបស់ អ.ជ.ត.ក នៅក្នុងសាលក្រមរបស់ខ្លួន[26] ហើយបានថ្លែងថា ការវាយតម្លៃបែបដូច្នេះ នឹងបានជួយសម្រួលដោយការកំណត់នូវការយល់ដឹងរបស់ខ្លួនស្តីពីធាតុផ្សំដែលបានបង្កើតឡើងនៃអំពើដែលជាមូលដ្ឋាន កាលណា

---

[23] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៧៦, ៥៧៨, ៥៨៤។ ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ("សាលក្រមសំណុំរឿង ០០២/០១") កថាខណ្ឌ ៤៣៥, ៤៣៧។ សំណុំរឿង ០០១-ឯកសារ **E188** សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ("សាលក្រម *ឌុច*") កថាខណ្ឌ ៣៦៧។ ឯកសារ **D427/1/30** សាលដីកាប្រឆាំងនឹងដីកាដំណោះស្រាយរបស់ អៀង សារី កថាខណ្ឌ ៣៧១-៣៧២, ៣៧៩-៣៨៥, ៣៩៨។ ឯកសារ **D427/2/15** សាលដីកាប្រឆាំងនឹងដីកាដំណោះស្រាយរបស់ នួន ជា និង អៀង ធីរិទ្ធ កថាខណ្ឌ ១៥៦-១៥៨, ១៦៥។ ឯកសារ **D427** ដីកាដំណោះស្រាយ កថាខណ្ឌ ១៣១៤, កំណត់សម្គាល់ជើងទំព័រលេខ ៥១៩៤។ *សូមអានផងដែរ* សាលដីកា *Stakić* កថាខណ្ឌ ៣១៥-៣១៦ កំណត់សម្គាល់ជើងទំព័រលេខ ៦៤៩។ សាលដីកា *Kordić & Čerkez* កថាខណ្ឌ ១១៧។ សាលដីកា *Brima* កថាខណ្ឌ ១៨៣, ១៩៨។

[24] ឯកសារ **E306/7/3** សេចក្តីសម្រេចស្តីពីសេចក្តីសន្និដ្ឋានរបស់សហមេធាវីនាំមុខអនុលោមតាមវិធាន៩២ ពាក់ព័ន្ធនឹងការបញ្ជាក់នៃវិសាលភាពនៃសំណុំរឿង០០២/០២ អំពីការចោទប្រកាន់បទរំលោភសេពសន្ថវៈស្ថិតក្នុងបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ។ ឯកសារ **D427/1/26** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ កថាខណ្ឌ ៧(២)។ ឯកសារ **D427/4/14** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ផ្នែកសម្រេចសេចក្តី កថាខណ្ឌ ២(២)។ ឯកសារ **D427/2/12** សាលដីកាលើបណ្តឹងឧទ្ធរណ៍ របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ផ្នែកសម្រេចសេចក្តី កថាខណ្ឌ ១(២)។

[25] ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៨០។

[26] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៧២៣-៧២៧។

ត្រូវបានកំណត់ "នៅក្នុងករណីចាំបាច់ ដើម្បីធានាដល់ការវិភាគសមស្រប"[27]។ អង្គជំនុំជម្រះសាលាដំបូង បានអះអាងថាពិតមែនហើយ វិធីសាស្ត្រនេះគឺកំពុងត្រូវបានធ្វើតាមដោយតុលាការអន្តរជាតិផ្សេងៗទៀត នៅពេលណាដែលមានការវាយតម្លៃលើអំពើអមនុស្សធម៌ផ្សេងៗទៀត (ការជន្លៀសដោយបង្ខំ) និងអំពើហិង្សាខាងផ្លូវភេទថាជាអំពើជាមូលដ្ឋានមួយនៃការធ្វើទុក្ខបុកម្នេញ[28]។

15. នៅក្នុងការកំណត់នូវការយល់ដឹងរបស់ខ្លួនស្តីពី "ធាតុផ្សំ" នៃអំពើដែលជាមូលដ្ឋាន អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថាមាននិយមន័យនៃការរំលោភសេពសន្ថវៈដែលមានលក្ខណៈរួមបញ្ចូល និងអព្យាក្រិត្យខាងផ្លូវភេទជាច្រើន ដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា នៅក្នុងសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន ក៏ប៉ុន្តែបានរកឃើញថា និយមន័យបែបមួយនេះបានទៅហួសពីការយល់ដឹងនៃការរំលោភសេពសន្ថវៈនៅក្នុងឆ្នាំ១៩៧៥[29]។ យោងទៅតាមអង្គជំនុំជម្រះនេះ នៅក្នុងឆ្នាំ១៩៧៥និយមន័យនៃការរំលោភសេពសន្ថវៈ បានតម្រូវឱ្យមានការដាក់បញ្ចូលអង្គជាតិក្នុងផ្លូវភេទរបស់ជនរងគ្រោះ[30]។ ហេតុដូច្នេះហើយ ពួកបុរសមិនអាចត្រូវបានថាជាជនរងគ្រោះពីការរំលោភសេពសន្ថវៈនៅក្នុងបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំនោះទេ[31] ដោយហេតុថាពួកគាត់មិនត្រូវបានគេស៊កបញ្ចូលអង្គជាតិក្នុងផ្លូវភេទនោះទេ។

16. បន្ទាប់មក អង្គជំនុំជម្រះបានសម្រេចដើម្បីវាយតម្លៃថាតើការបង្ខំបុរសឱ្យរួមភេទជាមួយដៃគូរបស់ខ្លួនក្រោយរៀបការរបស់ពួកគេ អាចកំណត់បានជាអំពើហិង្សាផ្លូវភេទដែលមានស្ថានទម្ងន់យ៉ាងធ្ងន់ធ្ងរដូច្នេះដែលមានតម្លៃស្មើនឹងអំពើអមនុស្សធម៌ផ្សេងៗទៀតដែរឬទេ[32]។ មិនដូចនិយមន័យនៃអំពើរំលោភសេពសន្ថវៈដែលបានអនុម័តដោយអង្គជំនុំជម្រះសាលាដំបូងទេ វាត្រូវបានកំណត់ថា អំពើហិង្សាផ្លូវភេទមិនតម្រូវឱ្យមានការបញ្ចូលអង្គជាតិទេ[33]។ អំពើហិង្សាផ្លូវភេទ ក៏ដាក់បញ្ចូលនូវអំពើ

---

[27] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៧២៧។

[28] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កំណត់សម្គាល់ជើងទំព័រលេខ ២២៣០។

[29] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៧៣០-៧៣១។ អង្គជំនុំជម្រះបានពឹងផ្អែកលើសំណុំរឿង ០០១-ឯកសារ **E188** សាលក្រម *ឌុច* កថាខណ្ឌ ៣៦២ ចំពោះនិយមន័យនេះ ដែលបានរៀបរាប់ *ក្នុងចំណោមនោះ* សាលដីកា *Kunarac* កថាខណ្ឌ ១២៧។ សាលក្រម *Semanza* កថាខណ្ឌ ៣៤៤-៣៤៥។ សាលក្រម *Sesay* កថាខណ្ឌ ១៤៥-១៤៦។ សាលក្រម *Furundžija* កថាខណ្ឌ ១៧៧។

[30] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៧៣១។

[31] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៧៣១។

[32] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២, កថាខណ្ឌ ៧៣១, ៣៧០១។

[33] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២, កថាខណ្ឌ ៣៧០១ *យោង* សាលក្រម *Akayesu* កថាខណ្ឌ ៦៨៨។

រួមភេទដែលលក្ខណៈផ្លូវភេទមិនមែនដោយរូបរាងកាយដែលធ្វើឲ្យអាម៉ាស់ និង/ឬ អាប់ឱនដល់ជនរងគ្រោះតាមរបៀបនៃការរួមភេទឡើយ[34]។ អង្គជំនុំជម្រះសាលាដំបូងបានរម្លឹកឡើងវិញថា ក្នុងការវាយតម្លៃលើអំពើប្រព្រឹត្ត "បញ្ហាដែលពាក់ព័ន្ធតែមួយគត់សម្រាប់ធ្វើការវាយតម្លៃ" គឺថាតើអំពើប្រព្រឹត្តនោះបានបំពេញតាមនិយមន័យនៃអំពើអមនុស្សធម៌ផ្សេងៗទៀត ស្របតាមតេស្តសាកល្បង-ធាតុផ្សំបីរបស់ អជតក ដែរឬអត់[35]។

17. ការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូង មាននៅក្នុងកថាខណ្ឌមួយនៃសាលក្រម ដូចខាងក្រោម៖

> អង្គជំនុំជម្រះយល់ពីអំពើហិង្សាផ្លូវភេទថា មានការពាក់ព័ន្ធទៅនឹង "ប្រភេទនៃអំពើនៃការរួមភេទណាមួយ ដែលបានប្រព្រឹត្តទៅលើបុគ្គលណាម្នាក់ក្រោមកាលៈទេសៈបង្ខិតបង្ខំ"[36]។ អង្គជំនុំជម្រះយល់ថាអំពើហិង្សាផ្លូវភេទ មិនកំណត់ត្រឹមការឃ្លានពានផ្នែករូបវ័ន្តទៅលើរូបរាយកាយរបស់មនុស្សណាម្នាក់ប៉ុណ្ណោះទេ ហើយអាចនឹងរួមបញ្ចូលទាំងអំពើទាំងឡាយដែលមិនពាក់ព័ន្ធនឹងការបញ្ចូលអង្គជាតិ ឬសូម្បីមិនមានការប៉ះពាល់ខាងរូបរាងកាយ[37]។ អង្គជំនុំជម្រះបានរកឃើញថា បុរសក៏មិនអាចបដិសេធមិនរួមភេទក្រោយការរៀបការដែរ។ មានពេលម្តងនោះ ប្តីបានរួមភេទជាមួយប្រពន្ធរបស់គាត់ ក្រោយពីមានការណែនាំរបស់*អង្គការ* និងដោយសារខ្លាចបាត់បង់ជីវិតខ្លួនឯង និងប្រពន្ធរបស់គាត់"[38]។ ភាគីដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បានទទួលនូវការឈឺចាប់យ៉ាងខ្លាំង ដោយសារតែគាត់មិនអាចរៀបការជាមួយស្ត្រីជាគូរដណ្តឹងរបស់គាត់[39]។ យ៉ាងណាមិញ **ដោយសារគ្មានភ័ស្តុតាងច្បាស់លាស់ទាក់ទងនឹងកម្រិត**

---

[34] *សូមមើល ជាឧទាហរណ៍* សាលក្រម *Akayesu* កថាខណ្ឌ ៦៨៨, សាលក្រម *Kvočka* កថាខណ្ឌ ១៨០, សាលដីកា *Đorđevic* កថាខណ្ឌ ៨៥០-៨៥២, សាលក្រម *Milutinović* កថាខណ្ឌ ភាគទី១, ២០១។

[35] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២, កថាខណ្ឌ ៧៣១-៧៣២។

[36] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២, កំណត់សំគាល់ជើងទំព័រ ១២៣២៥ *យោង* សាលក្រម *Akayesu* កថាខណ្ឌ ៦៨៨, សាលក្រម *Kvočka* កថាខណ្ឌ ១៨០។

[37] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កំណត់សំគាល់ជើងទំព័រ ១២៣២៦ *យោង* សាលក្រម *Akayesu* កថាខណ្ឌ ៦៨៨។

[38] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កំណត់សំគាល់ជើងទំព័រ ១២៣២៧ *យោង* កថាខណ្ឌ ៣៦៥៧ (ស៊ូ សុទ្ធារី)។

[39] ឯកសារ E465 សាលក្រមសំណុំរឿង ០០២/០២ កំណត់សំគាល់ជើងទំព័រ ១២៣២៨ *យោង* កថាខណ្ឌ ៣៦៨០ (យួស ផល)។

**នៃភាពធ្ងន់ធ្ងរនៃអំពើប្រព្រឹត្តប្រភេទនេះ និងផលប៉ះពាល់របស់វាទៅលើបុរស ទោះបីជាមានការទទួលស្គាល់ថា បុរសបានទទួលរងអំពើហិង្សាផ្លូវភេទ ដែលផ្ទុយពីសេចក្តីថ្លៃថ្នូររបស់មនុស្សក្តី ក៏អង្គជំនុំជម្រះមិនអាចឈានដល់ការសម្រេចមួយស្តីពីភាពធ្ងន់ធ្ងរខាងផ្លូវកាយ និងផ្លូវចិត្តដែលបុរសទាំងនោះ បានទទួលរងនូវការឈឺចាប់នោះដែរ។** ទន្ទឹមនេះ អង្គជំនុំជម្រះក៏មិនអាចឈានដល់ការសន្និដ្ឋានមួយអំពីបទដ្ឋានចាំបាច់ ទាក់ទងនឹងឧប្បត្តិហេតុទាំងនេះ និងក៏**មិនពិចារណាថា អំពើទាំងនោះគឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងៗ តាមរយៈអំពើហិង្សាផ្លូវភេទ**[40] នោះបានដែរ។

## IV. សេចក្តីសន្និដ្ឋាន

## ក. អង្គជំនុំជម្រះសាលាដំបូងមានកំហុសផ្នែកអង្គច្បាប់ដោយខកខានមិនបានអនុវត្តការសាល្បងស្តីពីអំពើអមនុស្សធម៌ផ្សេងៗទៀតឲ្យបានត្រឹមត្រូវ

18. អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គច្បាប់ដោយខកខានមិនបានវាយតម្លៃថាតើការបង្ខំបុរសឲ្យរួមភេទដោយខ្លួនឯង បង្កើតបានជាការវាយប្រហារធ្ងន់ធ្ងរទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្សដែលជាធាតុផ្សំដ៏សំខាន់មួយនៃតេស្តសាកល្បងនៃអំពើអមនុស្សធម៌ផ្សេងៗទៀត ដែរឬទេ។ ទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់យ៉ាងត្រឹមត្រូវអំពីធាតុផ្សំជាក់ស្តែងទាំងបី ក្នុងការធ្វើតេស្តសាកល្បងដើម្បីកំណត់អំពីអំពើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃអំពើអមនុស្សធម៌ផ្សេងៗទៀតក្តី[41] ក៏អង្គជំនុំជម្រះនៅតែខកខានមិនបានប្រើប្រាស់ធាតុផ្សំទីពីរឲ្យបានត្រឹមត្រូវ។ ធាតុផ្សំទីពីរតម្រូវឲ្យមានការរកឃើញមួយអំពីអំពើ ឬការខកខានដែលបានបង្កឲ្យមានឈឺចាប់ ឬរបួសធ្ងន់ធ្ងរទៅលើរាងកាយ ឬផ្លូវចិត្ត *ឬ* ដែលបង្កើតបានជាការវាយប្រហារ**យ៉ាងធ្ងន់ធ្ងរ**ប្រឆាំងនឹងសេចក្តីថ្លៃថ្នូររបស់មនុស្ស[42]។ ការប្រើការភ្ជាប់នេះ "ឬ" អនុញ្ញាតថា បើសិនជាអំពើ ឬការខកខាននោះ គឺជា"ការឈឺចាប់ ឬ របួសធ្ងន់ធ្ងរទៅលើរាងកាយ ឬ ផ្លូវចិត្ត" *ឬ* "ដែលបង្កើតបានជាការវាយប្រហារ**យ៉ាងធ្ងន់ធ្ងរ**

---

[40] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧០១ (សង្កត់ន័យដើម)។

[41] *សូមមើល* កថាខណ្ឌ ១៣-១៤, *ខាងលើ*។

[42] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២, កថាខណ្ឌ ៧២៤ (សង្កត់ន័យបន្ថែម)។ *សូមមើលផងដែរ* ឯកសារ **F36** សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ ៥៨០។ សេចក្តីព្រាងក្រមឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិរបស់គណៈកម្មការច្បាប់អន្តរជាតិ (ILC), ភាគ II, វគ្គពីរ, ឆ្នាំ១៩៩៦, ទំព័រ ៥០: "គំនិតនៃអំពើអមនុស្សធម៌ផ្សេងៗទៀតគឺត្រូវបានកម្រិតត្រឹមលក្ខខណ្ឌតម្រូវពីរ។ ទីមួយ អំពើប្រភេទនេះ គឺមានចេតនាបញ្ចូលតែអំពើបន្ថែមណាដែលមានស្ថានទម្ងន់ស្រដៀងគ្នានឹងអំពើដែលបានវាយឈ្មោះក្នុងអនុកថាខណ្ឌពីមុនប៉ុណ្ណោះ។ ទីពីរ ការពិត អំពើនោះត្រូវតែបានបង្កឲ្យមានរបួសដល់មនុស្ស ទៅលើបូរណភាពរាងកាយ ឬផ្លូវចិត្ត សុខភាព *ឬ* សេចក្តីថ្លៃថ្នូររបស់មនុស្ស" (សង្កត់ន័យដើម)។

ប្រឆាំងនឹងសេចក្តីថ្លៃថ្នូររបស់មនុស្ស"នោះ*អំពើពិរុទ្ធ*ត្រូវបានបង្ហាញជាភ័ស្តុតាង។ ការអានតាមន័យធម្មតាទៅលើអាណត្តិនៃលក្ខខណ្ឌតម្រូវនេះគឺថា បើសិនជាជម្រើសមួយមិនត្រូវបានបំពេញ ជម្រើសមួយផ្សេងទៀត ត្រូវតែយកមកវាយតម្លៃ។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានធ្វើដូច្នេះទេ ថ្វីបើខ្លួនបានថ្លែងថា "ខ្លួនមិនអាចឈានដល់ការសម្រេចអំពីភាពធ្ងន់ធ្ងរនៃការឈឺចាប់ផ្លូវកាយ ឬផ្លូវចិត្ត" ដែលបានកើតឡើងចំពោះបុរសទេ[43]។ កំហុសអង្គច្បាប់នេះធ្វើឲ្យមោឃៈដល់ការរកឃើញដែលថា អំពើដែលបុរសបានទទួលរង មិនបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងៗទៀតនោះទេ[44] ហើយកំហុសនេះតម្រូវឲ្យមានអន្តរាគមន៍ពីអជតក។

19. ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងអនុវត្តតាមអភិក្រមត្រឹមត្រូវសម្រាប់វាយតម្លៃលើធាតុផ្សំទីពីរនៃតេស្តសាកល្បងនៃអំពើអមនុស្សធម៌ផ្សេងៗទៀត អង្គជំនុំជម្រះអាចសន្និដ្ឋានថា ឧក្រិដ្ឋកម្មរួមមានអំពើប្រឆាំងនឹងជនរងគ្រោះជាបុរស។ សាលក្រមក្នុងរឿងក្តី *Čelebići* ជាជំនួយដូចដែលសាលក្រមនេះបានកំណត់ការវាយតម្លៃបានត្រឹមត្រូវ។ ទោះបីជា *Čelebići* ពាក់ព័ន្ធនឹងការប្រព្រឹត្តដោយអមនុស្សធម៌ (អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ) និងការប្រព្រឹត្តដោយឃោរឃៅ (ឧក្រិដ្ឋកម្មសង្គ្រាម) ក៏ដោយ ក៏ធាតុផ្សំនានាដែលបានតម្រូវឲ្យបង្ហាញសក្ខីកម្មពីឧក្រិដ្ឋកម្មទាំងនេះ គឺជាធាតុផ្សំដូចគ្នា ដែលបានតម្រូវឲ្យបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងៗទៀត[45] ហើយ "ការវាយប្រហារទៅលើសេចក្តីថ្លៃថ្នូររបស់បុគ្គល" គឺអាចប្រៀបធៀបគ្នាបានដែរ[46]។

---

[43] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២, កថាខណ្ឌ ៣៧០១។

[44] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២, កថាខណ្ឌ ៣៧០១។

[45] ក្នុងឆ្នាំ២០០២ អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Krnojelac* បានថ្លែងថា៖ "ជាក់ស្តែង តាមរយៈយុត្តិសាស្ត្ររបស់តុលាការនេះ គឺថា ការប្រព្រឹត្តយ៉ាងឃោរឃៅ ការប្រព្រឹត្តដោយអមនុស្សធម៌ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ជាមូលដ្ឋានតម្រូវឲ្យមានភ័ស្តុតាងដែលមានធាតុផ្សំដូចគ្នា។ [...] និយមន័យដែលអនុមតិសម្រាប់បទល្មើសនីមួយៗនៅក្នុងសេចក្តីសម្រេចរបស់តុលាការនេះ គឺខុសៗគ្នាអាស្រ័យទៅតាមកន្សោមពាក្យដែលបានប្រើ"។ *សូមមើល* សាលក្រម *Krnojelac* កថាខណ្ឌ ១៣០។ ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Simić* បានថ្លែងថា៖ "ដើម្បីវាយតម្លៃលើខ្លឹមសារនៃការប្រព្រឹត្តដោយឃោរឃៅ និងអមនុស្សធម៌ អង្គជំនុំជម្រះសាលាដំបូងរកឃើញថា ខ្លួនទទួលបានជំនួយពីយុត្តិសាស្ត្ររបស់តុលាការនេះទាក់ទងនឹងអំពើអមនុស្សធម៌ផ្សេងៗទៀត តាមមាត្រា ៥(i) នៃច្បាប់លក្ខន្តិកៈ, ការប្រព្រឹត្តដោយអមនុស្សធម៌ តាមមាត្រា ២(ខ) នៃច្បាប់លក្ខន្តិកៈ និងការប្រព្រឹត្តដោយឃោរឃៅ តាមមាត្រា ៣ នៃច្បាប់លក្ខន្តិកៈ។ ធាតុផ្សំនៃបទល្មើសទាំងនេះ គឺដូចគ្នា"។ *សូមមើល* សាលក្រម *Simić* កថាខណ្ឌ ៧៤។ *សូមមើលផងដែរ សាលក្រម* Naletilić & Martinović, កថាខណ្ឌ ២៤៦, សាលក្រម *Vasiljević*, កថាខណ្ឌ ២៣៤, សាលក្រម *Kordić & Čerkez*, កថាខណ្ឌ ២៦៥, សាលក្រម *Jelisić*, កថាខណ្ឌ ៥២, សាលក្រម *Karadžić*, កំណត់សំគាល់ជើងទំព័រ ១៦៣៤។ អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Karadžić* ក៏បានកត់សំគាល់ថា

20. នៅក្នុង *Čelebići* អង្គជំនុំជម្រះសាលាដំបូងត្រូវបានឲ្យបង្ហាញភស្តុតាងថា Mirko Kuljanin ត្រូវបានវាយធ្វើបាបយ៉ាងធ្ងន់ធ្ងរ នៅមុនពេលដែលគាត់ត្រូវបាននាំខ្លួនទៅកាន់ជំរុំឃុំឃាំង[47]។ នៅពេលដែលគាត់ទៅដល់លោក Kuljanin ត្រូវបានគេយកទៅកាន់ជញ្ជាំងមួយនៅខាងក្នុងបរិវេណជំរុំនោះ ជាទីកន្លែងដែលពួកអ្នកទោសផ្សេងៗទៀត ត្រូវបានវាយធ្វើបាប ក៏ប៉ុន្តែគាត់មិនមានលទ្ធភាពអាចឈរបាននោះទេ ដោយសារតែមុខរបួសពីមុនរបស់គាត់[48]។ នៅឯជញ្ជាំង លោក Kuljanin ត្រូវបានវាយធ្វើបាបជាច្រើនដងមុននឹងអាជ្ញាធរយកគាត់ចេញ[49]។ អង្គជំនុំជម្រះសាលាដំបូងនៃលោក *Čelebići* បានរកឃើញថា ខ្លួនមិនមានភស្តុតាងគ្រប់គ្រាន់នោះទេ មុននឹងខ្លួនវាយតម្លៃថាតើការវាយធ្វើបាបដែលលោក Kuljanin បានទទួលនៅក្នុងជំរុំនោះ បានបណ្តាលឲ្យគាត់ទទួលរងនូវការឈឺចាប់ ឬរងរបួសបែបណា ដែលជាលក្ខខណ្ឌតម្រូវឲ្យមាន ក្នុងការបង្កើតបានជាការបណ្តាលឲ្យរងនូវការឈឺចាប់យ៉ាងខ្លោចផ្សារ ឬរងរបួសយ៉ាងធ្ងន់ធ្ងរលើរាងកាយ ឬសុខភាពរបស់គាត់ ដោយចេតនា ដែរឬទេ[50]។ យ៉ាងណាក៏ដោយបន្ទាប់មក អង្គជំនុំជម្រះនេះបានបែរទៅរកជម្រើសមួយផ្សេងទៀត គឺលក្ខខណ្ឌតម្រូវនៃ *អំពើពិរុទ្ធ* ហើយបានរកឃើញថាអំពើសកម្មនៃការវាយធ្វើបាបនរណាម្នាក់ ដែលមានរបួសធ្ងន់ធ្ងររួចហើយនោះ ជាហេតុដែលគាត់មិនមានលទ្ធភាព

---

យុត្តិសាស្ត្ររបស់តុលាការ ICTY បានបង្កើតនិយមន័យនៃ ការប្រព្រឹត្តដោយឃោរឃៅ និង/ឬ អមនុស្សធម៌ ថាជាអំពើនៃបទល្មើសជាមូលដ្ឋាននៃការធ្វើទុក្ខបុកម្នេញ គឺដូចគ្នា (*សូមមើល* សាលក្រម *Karadžić* កំណត់សំគាល់ជើងទំព័រ ១៦៣៤ *យោង* សាលក្រម *Gotovina*, ភាគ II, កថាខណ្ឌ ១៧៩១, សាលក្រម *Tolimir*, កថាខណ្ឌ ៨៥៣, សាលក្រម *Popović*, កថាខណ្ឌ ៩៧៥)។ ដូច្នេះ នៅពេលពិនិត្យថាតើអំពើប្រព្រឹត្តណាមួយមានតម្លៃស្មើនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងៗដែរឬអត់ គេអាចយោងទៅរកការវិភាគលើអំពើទាំងនោះដោយវាយតម្លៃទៅនឹងការប្រព្រឹត្តដោយឃោរឃៅ (ដូចជាឧក្រិដ្ឋកម្មសង្គ្រាម) ឬ ការប្រព្រឹត្តដោយអនុស្សធម៌ (ដូចជា ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ) ដោយសារសញ្ញាណនៃបទល្មើសទាំងបី គឺមានអត្ថន័យផ្លូវច្បាប់ដូចគ្នា ហើយធាតុផ្សំបីដូចគ្នាក៏ត្រូវបានបង្កើតឡើង)។

[46] ការវាយប្រហារទៅលើសេចក្តីថ្លៃថ្នូររបស់បុគ្គលត្រូវបានកំណត់ថាជា "អំពើ ឬអំពើអកម្ម អាចពិចារណាជាទូទៅថាជាមូលហេតុបណ្តាលឲ្យមានការប្រមាថមាក់ងាយ បន្ទាបបន្ថោក ឬផ្សេងពីនេះទៀត គឺជាការវាយប្រហារធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្ស" សូមមើល *Kunarac* AJ កថាខណ្ឌ១៦៣ (សង្កត់ន័យបន្ថែមដោយគូសបន្ទាត់ពីក្រោម) ដោយបញ្ជាក់ថា *Kvočka* TJ កថាខណ្ឌ៥០៧) សូមមើលផងដែរ កថាខណ្ឌ១៦៩ ប្រៀបធៀប "ការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស" ចំពោះឧក្រិដ្ឋកម្មសង្គ្រាមនៃការវាយធ្វើបាបដោយអំពើអមនុស្សធម៌។

[47] សាលក្រម *Čelebići* កថាខណ្ឌ ១០២៤។

[48] សាលក្រម *Čelebići* កថាខណ្ឌ ១០២៥។

[49] សាលក្រម *Čelebići* កថាខណ្ឌ ១០២៥។

[50] សាលក្រម *Čelebići* កថាខណ្ឌ ១០២៦។

អាចក្រោកឈរបាននោះ ជាអប្បបរមាគឺជាការប្រមាថយ៉ាងធ្ងន់ធ្ងរទៅលើមនុស្សជាតិ[51]។ ដូច្នេះ ការវាយធ្វើបាបទៅលើរូបរាងកាយរបស់លោក Mirko Kuljanin ត្រូវបានរកឃើញថា ត្រូវទៅនឹងលក្ខខណ្ឌតម្រូវនៃ *អំពើពីរុទ្ធ* នៃការវាយធ្វើបាបដោយអមនុស្សធម៌ ក្រោមមាត្រា២ និងការវាយធ្វើបាបដោយឃោរឃៅ នៅក្រោមមាត្រា៣ នៃច្បាប់លក្ខន្តិកៈរបស់តុលាការ ICTY[52]។

21. នៅក្នុងសំណុំរឿង ០០២/០១ អភិក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ចំពោះការវាយប្រហារប្រឆាំងនឹងសេចក្ដីថ្លៃថ្នូររបស់មនុស្ស ថាជាអំពើអមនុស្សធម៌ផ្សេងមួយ បានជួយពង្រឹងទៅលើគោលការណ៍ថា ជម្រើសផ្សេងណាមួយអាចកំណត់ឲ្យឃើញដាច់ដោយឡែក និងដោយឯករាជ្យនៃ *អំពើពីរុទ្ធ* ពីអំពើអមនុស្សធម៌ផ្សេងៗទៀត។ នៅទីនោះ អង្គជំនុំជម្រះបានរកឃើញថា លក្ខខណ្ឌនានា នៅក្នុងអំឡុងនៃការជម្លៀសប្រជាជនដំណាក់កាលទីពីរ "បានបណ្ដាលឲ្យមានការឈឺចាប់យ៉ាងធ្ងន់ធ្ងរលើរាងកាយ និងផ្លូវចិត្ត" និងមិនបានវិភាគថាតើ អំពើនោះបង្កើតបានជា "ការវាយប្រហារយ៉ាងធ្ងន់ធ្ងរទៅលើសេចក្ដីថ្លៃថ្នូររបស់មនុស្ស" នោះទេ ដោយសារ បានបំពេញតាមលក្ខខណ្ឌតម្រូវនៃ *អំពើពីរុទ្ធ* នោះហើយ[53]។ យុត្តិសាស្ត្រ*ចំពោះកិច្ច* គាំទ្រចំពោះអភិក្រមនេះ៖ គឺថា បើសិនជាជម្រើសមួយត្រូវបានបំពេញហើយនោះ ការវិភាគចំពោះជម្រើសទីពីរមិនចាំបាច់ទេ[54]។ ផ្ទុយទៅវិញ នៅពេលជម្រើសទីមួយមិនបានបំពេញតាមលក្ខខណ្ឌតម្រូវ តាមរឿងក្ដី *Čelebići* និងករណីផ្សេងទៀត បង្ហាញថា ជម្រើសទីពីរត្រូវតែយកមកវាយតម្លៃ[55]។

---

[51] សាលក្រម *Čelebići* កថាខណ្ឌ ១០២៦។

[52] សាលក្រម *Čelebići* កថាខណ្ឌ ១០២៦។ *សូមអានផងដែរ* សាលដីកា *Čelebići* កថាខណ្ឌ ៤២៦-៤២៧ (គាំទ្រការកាត់ឲ្យជាប់ទោស តាមមាត្រា២ និង បដិសេធការកាត់ឲ្យជាប់ទោស តាមមាត្រា៣ ដោយសារការពិចារណាកាត់ឲ្យជាប់ទោសពីរដង/ត្រួតលើគ្នា)។ ដូចបានកត់សម្គាល់រួចហើយនៅក្នុងកំណត់សម្គាល់ជើងទំព័រ ៤៥ *ខាងលើ* ឧក្រិដ្ឋកម្មទាំងនេះ គឺប្រៀបប្រដូចបានទៅនឹងអំពើអមនុស្សធម៌ផ្សេងៗទៀត ដោយសារឧក្រិដ្ឋកម្មទាំងនោះមានធាតុផ្សំនៃភស្តុតាងដូចគ្នា។

[53] ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ ៦៤៤។

[54] *សូមមើលជាឧទាហរណ៍ សាលក្រម* Lukić & Lukić, កថាខណ្ឌ ៩៦៣-៩៦៦, សាលក្រម *D. Milošević*, កថាខណ្ឌ ៩៣៨, សាលក្រម *Kvočka*, កថាខណ្ឌ ២០៩, សាលក្រម *Naletilić & Martinović*, កថាខណ្ឌ ២៧១, ២៨៩, ៣០៣, សាលក្រម *Karadžić*, កថាខណ្ឌ ៥៦៤១, សាលក្រម *Mladić*, ភាគ ៣, កថាខណ្ឌ ៣២៩៣-៣២៩៤, សាលក្រម *Blaskić*, កថាខណ្ឌ ៧១៦, សាលក្រម *Ntagerura*, កថាខណ្ឌ ៨០០។

[55] ករណីនានាដែលអង្គជំនុំជម្រះបានពិចារណាតាមជម្រើសទាំងពីរ ប៉ុន្តែ*មិនបានបំពេញនូវលក្ខខណ្ឌណាមួយ* តាមរយៈភស្តុតាងនៅចំពោះមុខខ្លួននោះ រួមមាន៖សាលក្រម *Ntakirutimana*, កថាខណ្ឌ ៧៤៥, ភាគ៣, កថាខណ្ឌ ១១២១, ១២១១, សាលក្រម *Limaj*, កថាខណ្ឌ ៤៣២, សាលក្រម *Haradinaj*, កថាខណ្ឌ ១៧០។

22. ដូចការវិភាគក្នុងរឿងក្ដី *Čelebići* បង្ហាញដែរថាតើអំពើណាមួយបង្កើតបានជា "ការវាយប្រហារយ៉ាងធ្ងន់ធ្ងរទៅលើសេចក្ដីថ្លៃថ្នូររបស់មនុស្ស" ដែរឬអត់នោះ វាគឺជាការវាយតម្លៃសត្យានុម័តដែលអាចត្រូវបានធ្វើឡើងដោយអង្គជំនុំជម្រះសាលាដំបូង ដោយគ្មានភស្តុតាងអំពីការឈឺចាប់។ អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្ដី *Čelebići* បានរកឃើញថា *អំពើពិរុទ្ធ* បានបំពេញលក្ខខណ្ឌហើយ ដោយសារថាជាសត្យានុម័ត ការវាយនរណាម្នាក់ដែលមានរបួសយ៉ាងធ្ងន់ធ្ងររួចហើយ គឺជាការប្រមាថយ៉ាងធ្ងន់ធ្ងរទៅលើសេចក្ដីថ្លៃថ្នូររបស់មនុស្ស - មិនតម្រូវឱ្យមានភស្តុតាងជាក់លាក់នៃផលប៉ះពាល់ពីអំពើនោះទៅលើជនរងគ្រោះទេ[56]។ នៅក្នុងសាលក្រមដែលកំពុងមានបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា "បុរសបានទទួលរងអំពើហិង្សាផ្លូវភេទ ដែលផ្ទុយពីសេចក្ដីថ្លៃថ្នូររបស់មនុស្ស" ក៏ប៉ុន្តែខកខានមិនបានធ្វើការវាយតម្លៃជាសត្យានុម័តថាតើ អំពើនោះគឺជា "ការវាយប្រហារយ៉ាងធ្ងន់ធ្ងរទៅលើសេចក្ដីថ្លៃថ្នូររបស់មនុស្ស"។ ការខកខានមិនបានធ្វើដូច្នេះ ត្រូវបានបង្ហាញឡើងតាមរយៈសេចក្ដីថ្លែងយ៉ាងច្បាស់របស់អង្គជំនុំជម្រះថា "គ្មានភស្តុតាងច្បាស់លាស់ពាក់ព័ន្ធនឹងកម្រិតនៃភាពធ្ងន់ធ្ងរ និងផលប៉ះពាល់របស់វាទៅលើបុរសទេ"[57]។ តេស្តសាកល្បងជាសត្យានុម័តនេះ មិនតម្រូវឱ្យមានភស្តុតាងដូច្នេះទេ។

23. ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងបានអនុវត្តបទដ្ឋានច្បាប់ត្រឹមត្រូវតាមរយៈការពិនិត្យ ថាតើការបង្ខំឱ្យបុរសឱ្យរួមភេទដោយខ្លួនផ្ទាល់ បង្កើតបានជាការវាយប្រហារយ៉ាងធ្ងន់ធ្ងរប្រឆាំងនឹងសេចក្ដីថ្លៃថ្នូររបស់មនុស្ស អង្គជំនុំជម្រះអាចគ្រាន់តែសន្និដ្ឋានថាខ្លួនអាចធ្វើបាន។ ការបង្ខំបុរសឱ្យរួមភេទដោយមិនមានការយល់ព្រម គឺតាមសត្យានុម័ត ជាអំពើធ្ងន់ធ្ងរដូចអំពើផ្លូវភេទផ្សេងៗទៀតនៃប្រភេទនៃការរួមភេទ ដែលបានរកឃើញថា បានបង្កើតជា "ការវាយប្រហារយ៉ាងធ្ងន់ធ្ងរមួយទៅលើសេចក្ដីថ្លៃថ្នូររបស់មនុស្ស" ឬជាឧក្រិដ្ឋកម្មដែលអាចប្រៀបធៀបបាននៃ "ការវាយប្រហារមួយទៅលើសេចក្ដីថ្លៃថ្នូររបស់បុគ្គល"[58]។ ជាឧទាហរណ៍ នៅក្នុងរឿងក្ដី *Bagosora* ការស៊កបញ្ចូលដបទៅក្នុងយោនីនៃសាកសពអាក្រាតរបស់នាយករដ្ឋមន្ត្រី និងការដោះសម្លៀកបំពាក់របស់ស្ត្រីមុននឹងសម្លាប់ពួកគាត់ ត្រូវបានរកឃើញថា បង្កើតបានជាការវាយប្រហារយ៉ាងធ្ងន់ធ្ងរទៅលើសេចក្ដីថ្លៃថ្នូររបស់មនុស្ស ចំពោះឧក្រិដ្ឋកម្មនៃអំពើអមនុស្សធម៌ផ្សេងៗទៀត[59]។ នៅក្នុងរឿងក្ដី *Kunarac*

---

[56] សាលក្រម *Čelebići* កថាខណ្ឌ ១០២៦។

[57] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២, កថាខណ្ឌ ៣៧០១។

[58] *សូមមើល* កថាខណ្ឌ ១៩ ជាទូទៅ និងជើងទំព័រ ៤៦ ជាពិសេស ដូចយោងជើងទំព័រខាងលើ។

[59] សាលក្រម *Bagosora* កថាខណ្ឌ៧០៥ ៧១៧-៧១៨ ២២១៩-២២២២, ២២២៤។ *កត់សម្គាល់* ថាការកាត់ឱ្យជាប់ទោសចំពោះការប្រមាថលើវិសាលភាពរបស់នាយករដ្ឋមន្ត្រី ត្រូវបានកែប្រែឡើងវិញនៅលើបណ្ដឹងសាទុក្ខ ពីព្រោះវាបានកាត់ឱ្យ Bagosora ជាប់ទោសចំពោះទង្វើឧក្រិដ្ឋដែលគាត់មិនត្រូវបានចោទប្រកាន់ មិនមែនមកពីតម្រូវការនៃការវាយប្រហារយ៉ាង

ការបង្ខំជនរងគ្រោះឲ្យដោះសម្លៀកបំពាក់ ហើយឲ្យរាំស្រាតនៅលើតុ ខណៈដែលជនជាប់ចោទនៅលើសាឡុង បានអង្គុយមើល ហើយភ្លង់កាំភ្លើងទៅលើពួកគាត់ បង្កើតបានជាការវាយប្រហារមួយទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្ស[60]។ ក្នុងរឿងក្តី *Katanga & Chui* តាមការបញ្ជាក់ពីដីកាសម្រេចចោទប្រកាន់ អ.ប.ជ បានរកឃើញកំហឹងយ៉ាងខ្លាំងក្លាមួយទៅលើសេចក្តីថ្លៃថ្នូររបស់បុគ្គល នៅពេលដែលស្ត្រីម្នាក់ត្រូវបានបង្ខំឲ្យបង្ហាញដល់ពួកយុទ្ធជន នូវឃ្លាំងគ្រឿងសញ្ញាវុធ និងគ្រាប់រំសេវ ខណៈដែលកំពុងស្លៀកពាក់តែអាវ និងខោទ្រនាប់ ហើយក្រោយមកពាក់តែអាវ[61]។ ករណីផ្សេងៗទៀតបានរកឃើញថា ការធ្វើឲ្យអាម៉ាស់មុខ និងការប្រព្រឹត្តដោយបន្ទាបបន្ថោក[62] ការធ្វើពេស្យាចារដោយបង្ខំ[63] អំពើហិង្សាលើផ្លូវភេទ[64] និងភាពអាក្រាតដោយបង្ខំ[65] បង្កើតបានជាអំពើអមនុស្សធម៌ផ្សេងៗទៀត ឬជាបទល្មើសដែលអាចប្រៀបធៀបបានផ្សេងៗទៀត ដែលតម្រូវឲ្យមានធាតុផ្សំជាភស្តុតាងដូចគ្នាដែរ[66]។

---

ធ្ងន់ធ្ងរទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្សត្រូវបានកែប្រែនោះទេ។ តាមការពិតទៅ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានកត់សម្គាល់ជាពិសេសថា ការប្រមាថសាកសព "បង្កើតបានជាការប្រទុស្តយ៉ាងជ្រាលជ្រៅមួយទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្ស សមនឹងបានទទួលការផ្តន្ទាទោស ដោយចំហរពេញទីនៅក្រោមច្បាប់អន្តរជាតិ"។ *សូមអាន* សាដីកា *Bagosora* កថាខណ្ឌ ៧២៧-៧២៩។

[60] សាលក្រម *Kunarac* កថាខណ្ឌ ៧៦៦-៧៧៤, ៧៨១, ៧៨២។

[61] ការបញ្ជាក់អំពីដីកាសម្រេចចោទប្រកាន់ *Katanga & Chui* កថាខណ្ឌ ៣៧៣-៣៧៦។

[62] សាលក្រម *Kupreškić* កថាខណ្ឌ ៥៦៦។ សាលក្រម *Kvočka* កថាខណ្ឌ ២០៨។ សាលក្រម *Sesay* កថាខណ្ឌ ១៣០២-១៣០៥។ សេចក្តីសម្រេចលើករណីរបស់ *Iwańczuk ទល់នឹង ប្រទេសប៉ូឡូញ* កថាខណ្ឌ ៥៩-៦០ (ការស្វែងរកដោយសម្រាតខោអាវមិនត្រឹមត្រូវតាមគន្លងធម៌ ដែលនៅក្នុងនោះ អ្នកយាមគុកបានបំពានតាមពាក្យសំដី និងចំអកមើលងាយអ្នកដាក់ពាក្យសុំ បណ្តាលឲ្យកើតមានជាការប្រព្រឹត្តដោយបន្ថោកកិត្តិយស នៅក្នុងការបំពានលើមាត្រា៣ នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស)។

[63] សាលក្រម *Kupreškić* កថាខណ្ឌ ៥៦៦។ សាលក្រម *Kvočka* កថាខណ្ឌ ២០៨។

[64] សាលក្រម *Muvunyi* កថាខណ្ឌ ៥២៨ *ដោយលើកឡើងពី* សាលក្រម *Kamuhanda* កថាខណ្ឌ ៧១០។ សាលក្រម *Niyitegeka* កថាខណ្ឌ ៤៦៥-៤៦៧ (អំពើហិង្សាខាងផ្លូវភេទទៅលើរាងកាយស្ត្រីម្នាក់ដែលស្លាប់ នឹងបណ្តាលឲ្យមានការឈឺចាប់ខាងផ្លូវចិត្តចំពោះប្រជាជន Tutsi)។ សាលក្រម *Kajelijeli* កថាខណ្ឌ ៩១៦។ សាលក្រម *Brđanin* កថាខណ្ឌ ១០១២-១០១៣ (ការបង្ខំស្ត្រីម្នាក់ឲ្យស្រាតនៅចំពោះមុខពួកប៉ូលីស និងពួកទាហានដែលកំពុងហ៊ោកញ្ជ្រៀវ, ការយកកាំបិតទៅជន្លនឹងដោះរបស់ស្ត្រីបូស្នៀ-មូស្លីម និង ការទាមទារឲ្យពួកអ្នកជាប់ឃុំប្រព្រឹត្តស្នេហាជាមួយគ្នា បង្កើតបានជាការវាយប្រហារខាងផ្លូវភេទធ្ងន់ធ្ងរគ្រប់គ្រាន់ល្មមនឹងឡើងដល់កម្រិតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)។ សាលក្រម *Čelebići* កថាខណ្ឌ ១០៦៥-១០៦៦ (ការបង្ខំឲ្យបង-ប្អូនប្រុសប្រព្រឹត្តការបៀម ឬជញ្ជក់លិង្គគ្នា នៅចំពោះមុខពួកអ្នកជាប់ឃុំដូចគ្នា)។

[65] សាលក្រម *Brđanin* កថាខណ្ឌ ១០១៣ (ស្ត្រីដែលត្រូវបានបង្ខំឲ្យស្រាតនៅចំពោះមុខពួកប៉ូលីស និងពួកទាហានដែលកំពុងហ៊ោកញ្ជ្រៀវ)។ សាលក្រម *Nyiramasuhuko* កថាខណ្ឌ ៦១៣៤-៦១៣៥។

[66] ដូចបានពិភាក្សានៅក្នុង កថាខណ្ឌ ១៩ *ខាងលើ*។

24. ការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងមិនបានរកឃើញដោយសត្យានុម័តថា ការបង្ខំបុរសឱ្យរួមភេទ គឺជាការវាយប្រហារយ៉ាងធ្ងន់ធ្ងរទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្ស រំលោភគោលការណ៍ជាមូលដ្ឋាននៃច្បាប់មនុស្សអន្តរជាតិ និងច្បាប់សិទ្ធិមនុស្ស ដែលជា "ការការពារចំពោះសេចក្តីថ្លៃថ្នូររបស់មនុស្សគ្រប់រូប *មិនថាគាត់មានភេទជាអ្វីនោះទេ*"[67] ។ កំហុសអង្គច្បាប់នេះធ្វើឱ្យមោឃៈដល់សេចក្តីសម្រេចដែលថា អំពើនេះមិនមែនជាអំពើអមនុស្សធម៌ផ្សេងៗទៀត[68] និងតម្រូវឱ្យមានអន្តរាគមន៍របស់ អជតក។

## ២. អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ និងអង្គហេតុ ដោយខកខានមិនបានរកឃើញថា ការបង្ខំឱ្យបុរសរួមភេទ នាំឱ្យមានការឈឺចាប់ ឬព្យសនកម្មធ្ងន់ធ្ងរលើរាងកាយ ឬផ្លូវចិត្ត

25. នៅពេលធ្វើការវាយតម្លៃលើភាពធ្ងន់ធ្ងរនៃការឈឺចាប់ដែលបុរសទទួលរង អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គច្បាប់ ដោយខកខានមិនបានផ្តល់ការយល់ឃើញដែលមានសម្អាងហេតុទេ និងខកខានមិនបានពិចារណាលើភស្តុតាងដែលពាក់ព័ន្ធ និងមានកំហុសអង្គច្បាប់ ដោយខកខានមិនបានធ្វើសេចក្តីសន្និដ្ឋានមួយដែលមានហេតុផល ដែលអង្គជំនុំជម្រះអាចធ្វើបានដោយឈរលើមូលដ្ឋាននៃភស្តុតាង និងការរកឃើញផ្ទាល់របស់ខ្លួន[69]។ គ្មានអង្គជំនុំជម្រះដែលសមហេតុផលណាដែលអនុវត្តច្បាប់ត្រឹមត្រូវ និងដែលពិចារណាលើរាល់ភស្តុតាងទាំងអស់ អាចសន្និដ្ឋានថាជនរងគ្រោះជាបុរសមិនបានទទួលរងនូវការឈឺចាប់ ឬព្យសនកម្មផ្លូវកាយ ឬផ្លូវចិត្ត នោះទេ។ កំហុសទាំងអស់នេះបានធ្វើឱ្យមោឃៈសេចក្តីសម្រេចនេះ និងបង្កើតបានជាភាពអយុត្តិធម៌។

### *i. អង្គជំនុំជម្រះសាលាដំបូង ខកខានមិនបានផ្តល់ការយល់ឃើញដែលមានសម្អាងហេតុ និងភាពផ្ទុយគ្នាមិនសមស្របចំពោះភស្តុតាង និងការរកឃើញរបស់ខ្លួនផ្ទាល់*

---

[67] សាលក្រមក្នុងសំណុំរឿង *Furundžija* កថាខណ្ឌ១៨៣ (គូសបញ្ជាក់បន្ថែម)។ នៅក្នុងកថាខណ្ឌដូចគ្នានេះ អង្គជំនុំជម្រះសាលាដំបូងបានបន្តថា៖"គោលការណ៍នេះ មានបំណងការពារមនុស្សពីការប្រមាថយ៉ាងធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូរផ្ទាល់របស់ពួកគេ ថាតើការប្រមាថធ្ងន់ធ្ងរបែបនោះត្រូវបានធ្វើឡើងតាមរយៈការវាយប្រហារយ៉ាងខុសច្បាប់លើរាងកាយ ឬតាមរយៈការធ្វើឱ្យអាម៉ាស់មុខ ឬការបន្ទាបបន្ថោកកិត្តិយស សេចក្តីថ្លៃថ្នូរ ឬសុខុមាលភាពផ្លូវចិត្តរបស់មនុស្សក្តី"។

[68] ឯកសារ **E465** សាលក្រម សំណុំរឿង០០២/០២ កថាខណ្ឌ ៣៧០១។

[69] **E465** សាលក្រម សំណុំរឿង០០២/០២ កថាខណ្ឌ ៣៧០១។

26. អង្គជំនុំជម្រះសាលាដំបូង ខកខានមិនបានផ្តល់មូលហេតុគ្រប់គ្រាន់[70] ដើម្បីពន្យល់អំពីមូលហេតុដែលនាំឲ្យការសម្រេចក្នុងសាលក្រមរបស់ខ្លួន មានលក្ខណៈមិនគ្រប់គ្រាន់ ដើម្បីកំណត់អំពីការឈឺចាប់ធ្ងន់ធ្ងរ។ អង្គជំនុំជម្រះបានរកឃើញថា ជនរងគ្រោះជាបុរស៖

- ត្រូវបានបង្ខំឲ្យពាក់ព័ន្ធនៅក្នុងការរួមភេទ[71]។
- ត្រូវបានបង្ខំដែលបណ្តាលឲ្យមានការរួមភេទទៅលើសហព័ទ្ធរបស់ខ្លួន[72] ដែលធ្វើឲ្យសហព័ទ្ធនោះ ទទួលរងនូវការឈឺចាប់យ៉ាងធ្ងន់ធ្ងរខាងផ្លូវកាយ និងផ្លូវចិត្ត ឬរបួសស្នាម ហើយបង្កើតបានជាការវាយប្រហារយ៉ាងធ្ងន់ធ្ងរទៅលើសេចក្តីថ្លៃថ្នូររបស់ស្ត្រី[73]។

---

[70] *សូមមើលឧទាហរណ៍* ឯកសារ **D55/I/8** សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើសុំមោឃភាព ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ កថាខណ្ឌ២១ (និងយុត្តិសាស្ត្រខាងក្នុង) ("អង្គបុរេជំនុំជម្រះសន្និដ្ឋានថា សេចក្តីសម្រេចទាំងអស់របស់ស្ថាប័នតុលាការត្រូវមានសម្អាងហេតុ ដោយសារនេះជាបទដ្ឋានអន្តរជាតិ។")។ ឯកសារ **E176/2/1/4** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឲ្យចាត់ការជាបន្ទាន់តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ កថាខណ្ឌ ២៥ ("រាល់សេចក្តីសម្រេចតាមផ្លូវតុលាការទាំងអស់ មិនថាជាសេចក្តីសម្រេចផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរឡើយ ត្រូវតែប្រកាន់ខ្ជាប់នូវកាតព្វកិច្ចរបស់តុលាការក្នុងការផ្តល់សំអាងហេតុគ្រប់គ្រាន់")។ ឯកសារ **E50** សេចក្តីសម្រេចលើសំណើសុំដោះលែងបន្ទាន់របស់ នួន ជា ខៀវ សំផន និង អៀង ធីរិទ្ធ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌ ២៣-២៧ (និងយុត្តិសាស្ត្រនៅខាងក្នុង)។ សេចក្តីសម្រេចបដិសេធមិនអនុញ្ញាតឲ្យ Milutinović ប្តឹងឧទ្ធរណ៍ កថាខណ្ឌ ២២ ("ជាផ្នែកមួយនៃការជំនុំជម្រះប្រកបដោយយុត្តិធម៌ អង្គជំនុំជម្រះត្រូវតែចេញមតិយោបល់មានសម្អាងហេតុ។ លក្ខខណ្ឌតម្រូវនេះតម្រូវឲ្យអង្គជំនុំជម្រះ *ជាអាទិ៍* ត្រូវបញ្ជាក់ពីទស្សនៈរបស់ខ្លួនអំពី [...] កត្តាពាក់ព័ន្ធទាំងអស់នោះដែលអង្គជំនុំជម្រះសាលាដំបូងសមហេតុផលមួយ ត្រូវបានរំពឹងទុកថានឹងយកមកពិចារណាមុនពេលធ្វើសេចក្តីសម្រេច")។

[71] ឯកសារ **E465** សាលក្រម សំណុំរឿង០០២/០២ កថាខណ្ឌ៣៦៦០-៣៦៦១, ៣៦៩១, ៣៦៩២, ៣៦៩៦, ៣៣៩៨, ៣៦៩៩។

[72] អង្គជំនុំជម្រះបានសន្និដ្ឋាននៅក្នុងសំណុំរឿង០០១ ថានេះគឺជា "ការឈឺចាប់មួយក្នុងចំណោមការឈឺចាប់បំផុតដែលមនុស្សម្នាក់អាចប្រព្រឹត្តទៅលើមនុស្សម្នាក់ទៀត"។ *សូមមើល* សំណុំរឿង០០១-ឯកសារ **E188** សាលក្រម ឌុច កថាខណ្ឌ៣៦១ *ដកស្រង់ ជាអាទិ៍* សាលក្រមក្នុងរឿងក្តី *Kunarac* កថាខណ្ឌ៦៥៥។ សាលក្រមក្នុងរឿងក្តី *Sesay* កថាខណ្ឌ១៤៤។ *សូមមើលផងដែរ* អនុសញ្ញាទីក្រុងហ្សឺណែវ IV មាត្រា២៧ និងសេចក្តីអត្ថាធិប្បាយអមរបស់វា (កថាខណ្ឌ២ ប្រកាសដកខ្លួនចេញពីការអនុវត្តជាក់លាក់ដែលបានកើតឡើង ឧទាហរណ៍ ក្នុងអំឡុងពេលសង្គ្រាមលោកចុងក្រោយ នៅពេលដែលស្ត្រីជាច្រើនមិនអាចរាប់បាននៃគ្រប់អាយុទាំងអស់ និងសូម្បីតែកូនក្មេង ត្រូវទទួលរងការប្រមាថយ៉ាងធ្ងន់ធ្ងរនៃប្រភេទដ៏អាក្រក់បំផុតនោះ គឺ៖ ការរំលោភសេពសន្ថវៈដែលបានប្រព្រឹត្តឡើងនៅក្នុងពេលដែនដីដែលត្រូវបានគ្រប់គ្រង ការប្រព្រឹត្តឃោរឃៅគ្រប់បែបយ៉ាង ការបំផ្លាញរូបរាងកាយ ។ល។"។ ក្រម Lieber មាត្រា ៤៤ (ការរំលោភសេពសន្ថវៈទាំងអស់លើអ្នកតាំងទីលំនៅនៃប្រទេសដែលត្រូវបានឈ្លានពានត្រូវបានហាមឃាត់ ក្រោមទណ្ឌកម្មប្រហារជីវិត ឬ "ការដាក់ទណ្ឌកម្មធ្ងន់ធ្ងរផ្សេងទៀត ដែលអាចហាក់ដូចជាគ្រប់គ្រាន់សម្រាប់ទម្ងន់នៃបទល្មើសនោះ")។

[73] ឯកសារ **E465** សាលក្រម សំណុំរឿង០០២/០២ កថាខណ្ឌ៣៦៨៤, ៣៦៩១, ៣៦៩៧, ៣៦៩៨។

- ត្រូវបាន**ធ្វើឱ្យប៉ះទង្គិចយ៉ាងខ្លាំង** បណ្ដាលមកពីការរួមភេទដោយបង្ខំ[74]។
- ត្រូវបានគំរាម**កំហែង**សម្លាប់ចោល បើសិនមិនព្រមធ្វើតាម[75] និង
- ទន្ទឹមនេះ គឺមានការភ័យខ្លាចចំពោះការបាត់បង់ជីវិតរបស់ពួកគេ បើសិនពួកគេមិនរួមដំណេក[76]។

យ៉ាងណាក៏ដោយ អង្គជំនុំជម្រះគ្រាន់តែ"បានទទួលស្គាល់"ថា អំពើដែលបុរសបានទទួលរងគឺផ្ទុយពីសេចក្ដីថ្លៃថ្នូររបស់មនុស្ស ដោយថ្លែងថា ខ្លួនមិនអាចឈានដល់ការសម្រេចស្ដីពីភាពធ្ងន់ធ្ងរនៃឈឺចាប់[77]។ មិនអង្គជំនុំជម្រះសមស្របណាមួយដែលពិចារណាលើភស្តុតាង និងការរកឃើញរបស់ខ្លួនផ្ទាល់ផ្សេងពីនេះឡើយ ក្នុងសាលក្រម ដែលអាចឈានដល់ការធ្វើសេចក្ដីសន្និដ្ឋាននេះ។

27. ជាងនេះទៀត អង្គជំនុំជម្រះខកខានមិនបានផ្ដល់ការយល់ឃើញដែលមានសម្អាងហេតុលម្អិតអំពីការវិភាគរបស់ខ្លួនអំពីការឈឺចាប់ដែលបុរសបានទទួលរង នៅពេលពួកគេត្រូវបានគេបង្ខំឱ្យរួមភេទនៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំនោះទេ។ ទោះបីជាអង្គជំនុំជម្រះមានឆន្ទានុសិទ្ធិក្នុងការស្វែងរកភ័ស្តុតាងណាដែលមានលក្ខណៈគួរឱ្យជឿជាក់ជាងគេ្គី[78] និងសច្ចាធារណ៍ដែលអាចតវ៉ាបាន ដែលថាខ្លួនពិតជាបានធ្វើការវាយតម្លៃយ៉ាងត្រឹមត្រូវទៅលើភ័ស្តុតាងទាំងអស់ក៏ដោយ[79]។ ត្រូវតែច្បាស់លាស់ពីរបៀបដែលសម្អាងហេតុនីមួយៗ ត្រូវបានធ្វើឡើងយ៉ាងដូម្ដេច[80]។ ត្រង់ចំណុចនេះ អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានធ្វើទេ។ ផ្ទុយទៅវិញ ដោយគ្មានការពន្យល់សោះ អង្គជនុំជម្រះសាលាដំបូង បានមើលរំលងភ័ស្តុតាងផ្ទាល់ដែលពាក់ព័ន្ធជាក់ស្ដែងទៅនឹងការវិភាគ និងបានទាត់ចោលភ័ស្តុតាងប្រយោលទាំងអស់ ឬបានផ្ដល់ទម្ងន់តិចតួចមិនមានសមាមាត្រ[81]។ អង្គជំនុំជម្រះគ្មានឆន្ទានុសិទ្ធិក្នុងការមិនអើពើចំពោះផ្នែកយ៉ាងធំនៃភ័ស្តុតាងដែលពាក់ព័ន្ធ ដែលជាភ័ស្តុតាងផ្ទុយ

[74] ឯកសារ **E465** សាលក្រម សំណុំរឿង០០២/០២ កថាខណ្ឌ៣៦៨៣ (គូសបញ្ជាក់បន្ថែម), ៣៦៨៤។

[75] ឯកសារ **E465** សាលក្រម សំណុំរឿង០០២/០២ កថាខណ្ឌ៣៦៥៣, ៣៦៩៦។

[76] ឯកសារ **E465** សាលក្រម សំណុំរឿង០០២/០២ កថាខណ្ឌ៣៦៩៦។

[77] ឯកសារ **E465** សាលក្រម សំណុំរឿង០០២/០២ កថាខណ្ឌ៣៧០១។

[78] សាលដីកាក្នុងរឿងក្ដី *Muvunyi* I កថាខណ្ឌ១៤៤។

[79] ឯកសារ **F36** សាលដីកាលើសំណុំរឿង ០០២/០១ កថាខណ្ឌ៣០៤ (និងយោងសម្អាងខាងក្នុង)។

[80] សាលដីកាលើសំណុំរឿង *Bemba* កថាខណ្ឌ៥២។ សាលដីកាលើសំណុំរឿង *Kordić & Čerkez* កថាខណ្ឌ៣៨៥។ សាលដីកាលើសំណុំរឿង កថាខណ្ឌ៤១។

[81] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ៣៧០១។ សូមមើលផងដែរ ផ្នែក IV.B ii ខាងក្រោមសម្រាប់សេចក្ដីលម្អិតអំពីភ័ស្តុតាងដែលត្រូវបានមើលរំលង។

ទៅនឹងការរកឃើញរបស់ខ្លួនដែលគ្មានការពន្យល់អំពីមូលហេតុ ហេតុអ្វីបានជាភ័ស្តុតាងនោះត្រូវបានបំភ្លិចចោល ហើយទទួលយកភស្តុតាងដែលបានជ្រើសរើស[82]។ លើសពីនេះ ការវិភាគណាមួយដែលកម្រិតត្រឹមតែផ្នែកចោះៗនៃកំណាត់ហេតុភ័ស្តុតាងពាក់ព័ន្ធ គឺមិនគ្រប់គ្រាន់ទេ ដើម្បីបង្កើតបានជាការយល់ឃើញដែលមានសម្អាងហេតុនោះ[83]។ ឧទាហរណ៍ជាក់លាក់អំពីភ័ស្តុតាងដែលអង្គជំនុំជម្រះបានមើលរំលង ឬផ្តល់ទម្ងន់មិនគ្រប់គ្រាន់ ត្រូវបានរៀបរាប់យ៉ាងលម្អិតនៅក្នុងផ្នែក IV.B ii ខាងក្រោម។

*ii. អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានពិចារណាលើភ័ស្តុតាងពាក់ព័ន្ធនៅក្នុងសំណុំរឿង*

28. ដោយគ្មានការពន្យល់ អង្គជំនុំជម្រះសាលាដំបូងបានមើលរំលងភ័ស្តុតាងផ្ទាល់ ដែលទាក់ទងទៅនឹងការសន្និដ្ឋានរបស់ខ្លួនលើការឈឺចាប់របស់បុរស។ អង្គជំនុំជម្រះក៏បានដាក់បន្ទុកនៃការបង្ហាញភ័ស្តុតាងខ្ពស់ហួសហេតុ តាមរយៈការតម្រូវពិសេសលើភ័ស្តុតាងផ្ទាល់អំពីការឈឺចាប់ ខណៈដែលទាត់ចោលភ័ស្តុតាងប្រយោយទាំងស្រុង ឬជាពិសេសនោះ បានផ្តល់នូវទម្ងន់តិចតួចមិនសមស្រប[84]។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូង បានពិចារណាត្រឹមត្រូវនូវរាល់ភ័ស្តុតាងទាំងអស់ នៅក្នុងសំណុំរឿងនេះ នៅក្នុងការវាយតម្លៃរបស់ខ្លួននោះ សេចក្តីសន្និដ្ឋានតែមួយគត់ដែលអង្គជំនុំជម្រះ

---

[82] វិធាន ១០១(១)(ក) នៃវិធានផ្ទៃក្នុង (“១. សាលក្រមត្រូវចែកជាពីរផ្នែក៖ ក) ផ្នែកសម្អាងហេតុ គឺជាការយល់ឃើញអំពីមូលហេតុខាងអង្គហេតុ និងអង្គច្បាប់ដែលនាំឲ្យអង្គជំនុំជម្រះចេញសេចក្តីសម្រេច”)។ ឯកសារ **F36** សាលដីកាលើសំណុំរឿង ០០២/០១ កថាខណ្ឌ៣០៤។ សាលដីកាក្នុងរឿងក្តី *Muvunyi* I កថាខណ្ឌ១៤៤, ១៤៧។ សាលដីកាក្នុងរឿងក្តី *Gotovina & Markač* កថាខណ្ឌ៦១។

[83] សាលដីកាក្នុងរឿងក្តី *Perišić* កថាខណ្ឌ៩២, ៩៥។ ក្នុងឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ៣៧០១ អង្គជំនុំជម្រះផ្តល់មូលដ្ឋានចំនួនបីនៃភ័ស្តុតាងដែលខ្លួនបានពិចារណាដើម្បីធ្វើការសន្និដ្ឋានរបស់ខ្លួន៖ (i) ការសន្និដ្ឋានរបស់ខ្លួន “ថាបុរសក៏មិនអាចបដិសេធការរួមដំណេកបានដែរ” (ទោះបីជាពាក្យពេចន៍នេះមិនស៊ីគ្នាទៅនឹងការសន្និដ្ឋានណាមួយត្រង់កន្លែងផ្សេងទៀតនៅក្នុងសាលក្រមនេះ ហើយអង្គជំនុំជម្រះមិនបានបញ្ជាក់ថាការសន្និដ្ឋានបែបនេះត្រូវបានធ្វើឡើងនៅក្នុងកថាខណ្ឌមួយណាក្តី ការសន្និដ្ឋានដែលទំនងជាសមគ្នាបំផុតនោះគឺត្រង់កថាខណ្ឌ ៣៦៩៦ ដែលថ្លែងថា “ទាំងបុរសទាំងនារីបានទទួលរងអារម្មណ៍ថា ត្រូវបង្ខិតបង្ខំឲ្យរួមភេទជាមួយប្តី ឬប្រពន្ធថ្មីថ្មោងរបស់ពួកគេ” ដែលត្រូវបានផ្អែកលើភ័ស្តុតាងដែលត្រូវបានពិភាក្សានៅក្នុងផ្នែក “បរិយាកាសបង្ខិតបង្ខំ” និង “ការរួមដំណេកដោយបង្ខំរវាងប្តីប្រពន្ធ” នៃសាលក្រមនេះ។ (ii) សក្ខីកម្មរបស់សាក្សីខ្មែយឈ្មោះ ស៊ូ សុធារី អំពីការរួមដំណេកក្នុអាពាហ៍ពិពាហ៍ដោយបង្ខំរបស់ខ្លួនជាមួយស្ត្រីម្នាក់ និង (iii) ភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី យស់ ផល អំពីវិប្បដិសារីដែលគាត់មានតាមរយៈការត្រូវបានបង្ខំឲ្យរៀបការជាមួយជាមួយមនុស្សម្នាក់ ដែលមិនមែនជាគូដណ្តឹងរបស់គាត់ (កត់សម្គាល់ថា យស់ ផល មិនបានសន្មត់ថាការឈឺចាប់របស់គាត់មកពីការដែលត្រូវបង្ខំឲ្យរួមដំណេកក្នុងអាពាហ៍ពិពាហ៍ដោយការរួមភេទនោះទេ។ គាត់បានសន្មតថាវាកើតឡើងដោយសារការដែលត្រូវរៀបការជាមួយអ្នកដែលគាត់មិនស្រឡាញ់ ខណៈដែលគាត់នៅតែស្រឡាញ់គូដណ្តឹងរបស់គាត់)។

[84] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ៣៧០១។

អាចគ្រាន់តែសន្និដ្ឋានថា ការឈឺចាប់ផ្លូវចិត្ត និងផ្លូវកាយដែលបុរសបានទទួលរងគ្រោះនោះ គឺមានលក្ខណៈ "ធ្ងន់ធ្ងរ" និងថា អំពើដែលបានប្រព្រឹត្តឡើង គឺមានភាពធ្ងន់ធ្ងរស្រដៀងគ្នាទៅនឹងអំពើផ្សេងៗទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

29. អង្គជំនុំជម្រះខកខានមិនបានពិចារណាភ័ស្តុតាងពាក់ព័ន្ធផ្ទាល់អំពីការឈឺចាប់របស់បុរស ដែលបានបណ្តាលមកពីជនរងគ្រោះនៃការរួមភេទដោយបង្ខំ និងតម្រូវឱ្យបង្កការឈឺចាប់នោះទៅលើមនុស្សដោយការឈឺចាប់ដល់ស្លាប់។ ឧទាហរណ៍ មិនមាននៅត្រង់ចំណុចណាមួយនៃការវិភាគរបស់ខ្លួនដែលអង្គជំនុំជម្រះបានពិចារណាអំពីសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន ដែលថារូបគាត់ និងភរិយារបស់គាត់ បានរួមសង្វាសដោយសារតែ "ស្ថិតក្រោមការតាមដាន" និងដោយសារខ្លាចគេសម្លាប់[85]។ គាត់បានរំលឹកថា ទោះបីជាសម្ពាធបែបនេះក្តី គាត់មានការឈឺចាប់ណាស់ចំពោះការសម្រេចចិត្តរួមសង្វាស៖

> [...] **អ៊ីចឹងក្នុងចំណុចនេះ ពេលដែលខ្ញុំស្រក់ទឹកភ្នែក ដោយសារទាំងប៉ុន្មានដោយសារនឹកឃើញរឿងអតីតកាល ថាខ្ញុំចុះជាបុរស ប៉ុន្តែគ្នាជាស្រីក៏ជួបរឿងដូចខ្ញុំដែរ រហូតដល់គ្នាបង្ខំចិត្តមនុស្សមិនស្រឡាញ់។** ប៉ុន្តែក្នុងឱកាសនោះខ្ញុំគិតឃើញ ប៉ុន្តែសួរគ្នា ដេកសួរគ្នា តើយើងធ្វើម៉េច? បើយើងដកដៃយើងនឹងងាប់ តើយើងធ្វើម៉េច? ហើយការនិយាយនេះ មិនបាននិយាយឱ្យគេឮទៀត។ មើលតើពិចារណា ហ្នឹងមានតែយើងពីរនាក់បង្ខំចិត្ត ទាំងងាប់ ទាំងរស់ដើម្បីបំពេញបំណងៗអ្នកត្រូវការដើម្បីជីវិតរបស់យើង យើងគួរធ្វើអ៊ីចឹងដែរ ឬអត់?
>
> **មុននឹងការរួមដំណេកជាមួយប្រពន្ធនេះ ខ្ញុំត្រូវប្រើអស់ជាងកន្លះខែ ទំរាំការរួមដំណេកសម្រេចចិត្តថាត្រូវតែយក។ ទាំងគាត់ក៏អ៊ីចឹង ទាំងខ្ញុំក៏អ៊ីចឹង អ៊ីចឹងមានរឿងកំសត់វេទនាលំបាកវេទនានេះរហូតដល់ថ្ងៃនេះ** ខ្ញុំនៅតែមិនទាន់រកឃើញអំពើទាំងហ្នឹងថាមកពីណា? ហើយខ្ញុំឃើញអំពើទាំងអស់នេះ ខ្ញុំមិនមែនមានន័យថាខ្ញុំចង់សងសឹក ខ្ញុំចងចងកម្មពារជាមួយ អត់ទេ តែខ្ញុំគ្រាន់តែមានគំនិតមួយថាបុគ្គលដែលនាំធ្វើអ៊ីចឹងគួរនាំដល់ណាទៀត? [...]។ តែខ្ញុំនឹកឃើញថ្ងៃនេះបើសិនជាជួបអ៊ីចឹងទៀត តើបុគ្គលដែលអ្នកជួបរបបប្រភេទនេះ តើអ្នករងគ្រោះប៉ុន្មានទៀត[86]។

---

[85] ឯកសារ **E1/113.1** អែម អឿន ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ ម៉ោង 15.57.58-16.01.45។

[86] ឯកសារ **E1/113.1** អែម អឿន ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ ម៉ោង 15.57.58-16.01.45 (គូសបញ្ជាក់បន្ថែម)។

ភ័ស្តុតាងរបស់ អែម អឿន ត្រូវបានផ្អែកនៅក្នុងការវិភាគរបស់អង្គជំនុំជម្រះអំពីការព្រមព្រៀងសម្រាប់អាពាហ៍ពិពាហ៍ដោយបង្ខំ[87] និងផលប៉ះពាល់នៃអាពាហ៍ពិពាហ៍ដោយបង្ខំ[88]។ ប៉ុន្តែដោយមិនមានការពន្យល់ អង្គជំនុំជម្រះបានមើលរំលងភ័ស្តុតាងនេះ នៅពេលដែលវាយតម្លៃពីភាពធ្ងន់ធ្ងរនៃការឈឺចាប់របស់បុរស ដែលបណ្តាលមកពីការរួមសង្វាសដោយបង្ខំ[89]។ ជាងនេះទៀត អង្គជំនុំជម្រះ បានខកខានមិនបានផ្តល់សម្អាងហេតុណាមួយអំពីមូលហេតុ ដែលការណ៍នេះមិនបង្កើតបានជា "ភ័ស្តុតាងច្បាស់លាស់ដែលទាក់ទងនឹងកម្រិតនៃភាពធ្ងន់ធ្ងរនៃអំពើប្រភេទនេះ"[90]។

30. ការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងអំពីការឈឺចាប់របស់បុរស ក៏បានមើលរំលងភ័ស្តុតាងពាក់ព័ន្ធពីសាក្សីជំនាញ Kasumi Nakagawa ផងដែរ។ ផ្អែកលើការសិក្សាស្រាវជ្រាវយ៉ាងទូលំទូលាយរបស់គាត់ និងរបស់អ្នកផ្សេងទៀត[91] Kasumi Nakagawa បានផ្តល់សក្ខីកម្មថា ការរួមភេទដោយបង្ខំមានផលប៉ះពាល់ស្មារតីធ្ងន់ធ្ងរ និងយូរអង្វែងលើជនរងគ្រោះ ជាពិសេសបុរស៖

> សៈ ដូច្នេះ ការដែលមានគេឃ្លាំមើលថាតើប្តីប្រពន្ធហ្នឹងរួមដំណេកឬអត់នោះ លោកស្រីកត់សម្គាល់ឃើញថា ចំណុចនេះវាបង្កព្យសនកម្ម ឬបង្កការឈឺចាប់ទៅដល់បុគ្គលដែលលោកស្រីបានសម្ភាសទេ?
>
> ឆៈ ចាស វាមានផលប៉ះពាល់យ៉ាងខ្លាំង ហើយការប៉ះពាល់នេះមិនស្មើគ្នាទៅនឹងបុរស ដោយសារបុរសមានភារកិច្ច ហើយត្រូវគេបង្ខំឱ្យរំលោភប្រពន្ធរបស់ខ្លួន [...]
>
> ការបង្ខំបុរសឱ្យរំលោភអ្នកណាម្នាក់ហ្នឹង គឺជាអំពើអមុស្សធម៌ មិនមែនបុរសទាំងអស់អាចធ្វើបានទេ ជាបឋមនោះ។ ប៉ុន្តែគេបង្ខំអ្នកនោះធ្វើបែបនោះ។ ការភ័យខ្លាចគឺជាកត្តា

---

[87] *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ១២០៩២ ក្នុងផ្នែក ១៤.៣.៦.២ ការព្រមព្រៀង។

[88] *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ជើងទំព័រ ១២២៧៤, ១២២៨៧ ក្នុងផ្នែក ១៤.៣.១២.១ ផលប៉ះពាល់នៃ "អាពាហ៍ពិពាហ៍ដោយបង្ខំ"។

[89] *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ផ្អែក ១៤.៣.៨.២, ១៤.៣.៨.៣, ១៤.៣.១២.២ កថាខណ្ឌ ៣៧០១។ ដូចដែលបានកត់សម្គាល់ក្នុងកថាខណ្ឌ ៣៣ *យោងខាងក្រោម* ផ្នែក ១៤.៣.៨.២ (បរិយាកាលបង្ខិតបង្ខំ) និង ១៤.៣.៨.៣ (ការរួមដំណេកដោយបង្ខំរវាងប្តីប្រពន្ធ) គឺជាភ័ស្តុតាងគាំទ្រដែលបានសន្មតសម្រាប់មូលដ្ឋានភ័ស្តុតាងបឋមរបស់អង្គជំនុំជម្រះសាលាដំបូង "ថាបុរសក៏មិនអាចបដិសេធការរួមដំណេកបានដែរ"។

[90] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ៣៧០១ (ថ្លែងថា "គ្មាន" ភ័ស្តុតាងបែបនេះ)។

[91] ទាក់ទងនឹងការសិក្សាស្រាវជ្រាវផ្ទាល់ខ្លួនរបស់គាត់ *សូមមើល* ឯកសារ **E1/472.1** Kasumi Nakagawa ប្រតិចារឹក ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 09.49.58-10.09.30, 14.15.45-14.16.57។ *សូមមើលផងដែរ* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ៣៥៣៤ (បានសន្និដ្ឋានថាមតិយោបល់របស់ Kasumi Nakagawa "ជាទូទៅ មានហេតុផលត្រឹមត្រូវ និងភាពស្របគ្នា" និង "បង្ហាញនូវការប្រុងប្រយ័ត្នក្នុងការសន្និដ្ឋាន ដោយលើកឡើងត្រឹមតែអ្វីដែលគាត់បានរកឃើញនៅក្នុងការស្រាវជ្រាវរបស់គាត់។"។

ដែលមិនអាចរស់រវើងបាន។ ហើយស្ត្រីជាច្រើនគាត់ភ័យខ្លាចខ្លាំងណាស់ ឬមួយក៏ពួកគេ បង្ហាញមនោសញ្ចេតនាថា ពួកគេមិនចង់ទទួលប្តីនោះទេ។ ហើយកាលៈទេសៈដ៏អាក្រក់បំផុតនោះ ដែលបុរសនោះត្រូវតែធ្វើ។ នោះគឺជាអំពើអមនុស្សធម៌។ ហើយខ្ញុំមិនអាចស្រម៉ៃ ឬអាំចគិតបានទេថា បុរសអាចធ្វើបែបនោះបាន។ ហើយប្រហែលជានោះហើយ គឺជាមូលហេតុដែលបុរសជាច្រើន ត្រូវបានគេបញ្ជូនទៅមន្ទីរអប់រំ កែប្រែ ដោយសារតែខកខានមិនបានរំលោភប្រពន្ធ។ អ៊ីចឹងគឺថា វាប៉ះពាល់ជាវិតអាពាហ៍ពិពាហ៍ បុរសជាប្តីនោះអាចមានអារម្មណ៍ថា មានកំហុសចំពោះប្រពន្ធ ឬមួយក៏មានការព្រួយបារម្ភ គឺថាក្នុងចិត្តរបស់ខ្លួនហ្នឹង គឺថាគិតថាប្រពន្ធមិនបានស្រឡាញ់ខ្លួនទេ។ វាអាចមានជំងឺបាក់ស្បាតក្នុងចិត្តរបស់គាត់ក្នុងរយៈពេលវែង រហូតដល់តែពេលគាត់ទទួលបានភាពជាបុរសឡើងវិញ ដែលគាត់អាចធានាថា ប្រពន្ធរបស់គាត់ទទួលយកគាត់ជាប្តីបាន។ ដូច្នេះហើយ នេះគឺជាផលប៉ះពាល់ដ៏ធំទៅលើបុរសដែលរងការបង្ខិតបង្ខំនោះ ហើយវាពិតជាអំពើអមនុស្សធម៌ប្រឆាំងនឹងបុរស។ [...] តាមគំនិតរបស់ខ្ញុំ គឺជាការរំលោភសេពសន្ថវៈដោយស្របច្បាប់។ គឺថាការរំលោភត្រូវតែធ្វើឲ្យបានសម្រេចដើម្បីគោរពតាមបញ្ជារបស់ខ្មែរក្រហម[92]។

31. អង្គជំនុំជម្រះសាលាដំបូងបានផ្អែកលើសក្ខីកម្មខាងលើរបស់ Kasumi Nakagawa ក្នុងផ្នែក ១៤.៣.១២.២ នៃសាលក្រម (ផលប៉ះពាល់នៃការរួមភេទដោយបង្ខំលើជនរងគ្រោះ)[93] ប៉ុន្តែខកខានមិនបានចាត់ទុកថាជាផ្នែកមួយនៃមូលដ្ឋានភ័ស្តុតាងសម្រាប់ការវិភាគរបស់ខ្លួន អំពីការឈឺចាប់របស់បុរសនោះទេ។ សក្ខីកម្មនេះពិតជាបានលើកឡើងផ្ទាល់អំពីភាពធ្ងន់ធ្ងរ និងផលប៉ះពាល់នៃការឈឺចាប់ដែលបុរសបានជួបប្រទះ ដែលជាលទ្ធផល មកពីការបង្ខំឲ្យរួមភេទ ដែលមិនមានក្នុងការវិភាគ បង្ហាញឲ្យឃើញថា អង្គជំនុំជម្រះមិនបានពិចារណាទាល់តែសោះ[94]។

---

[92] *សូមមើល* ឯកសារ **E1/472.1** Kasumi Nakagawa ប្រតិចារឹក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង៖ ១៥.៤៣.១៣-១៥.៤៨.២៧, ១៥.៥១.២០-១៥.៥២.៣៥ (*ដោយបានលើកឡើង* ជាផ្នែកនៅក្នុងឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កំណត់សម្គាល់ជើងទំព័រលេខ ១២២៨៩ ក៏ប៉ុន្តែមិនបានយោងនៅក្នុងកថាខណ្ឌ ៣៧០១ ទេ)។ *សូមមើលផងដែរ* Rumney, P.N. និង Morgan-Taylor, M. (ឆ្នាំ១៩៩៧) 'ការទទួលស្គាល់ជនរងគ្រោះជាបុរស៖ អព្យាក្រឹត្យភាព-យ៉េនឌ័រ និងច្បាប់ស្តីពីការរំលោភសេពសន្ថវៈ៖ ភាគ២ *Anglo-American Law Review* 26: ទំព័រ ៣៣០-៣៥៦ នៅត្រង់ ៣៤៦ ("ទង្វើដែលទាក់ទងនឹងបុរស ដែលត្រូវបានតម្រូវឲ្យស៊កបញ្ចូលទៅក្នុងអ្នកមួយផ្សេងទៀត ទំនងជាមានលទ្ធភាពអាចបង្កើតបានជាកម្រិតធ្ងន់ធ្ងរនៃការប៉ះទង្គិច ហើយមិនអាចត្រូវបានបដិសេធយ៉ាងងាយស្រួលបាននោះឡើយ ពីព្រំដែននៃការរំលោភសេពសន្ថវៈ។ ការប្រទុស្តបែបដូច្នេះ ដោយឡែកអាចជាការប៉ះទង្គិច ពីព្រោះវាបានឡើងដល់ស្ថានភាពមួយ ដែលនៅក្នុងនោះ បុរសត្រូវបានបង្ខំឲ្យទ្រាំទ្រយ៉ាងសកម្មនឹងការស៊កបញ្ចូលរហូតដល់ចំណុចចេញទឹកកាម")។

[93] *សូមមើល* ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ៣៦៨៤។

[94] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ៣៧០១។

32. បន្ថែមលើការខកខានរបស់អង្គជំនុំជម្រះក្នុងការពិចារណាលើភស្តុតាងផ្ទាល់ដែលពាក់ព័ន្ធ ដែលបានរៀបរាប់ខាងលើ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធខុសចំពោះភស្តុតាងប្រយោល នៅក្នុងការវិភាគរបស់ខ្លួនអំពីការឈឺចាប់របស់បុរស។ ការសន្និដ្ឋានរបស់អង្គជំនុំជម្រះថា "អវត្តមានភស្តុតាង*ច្បាស់លាស់*" អំពីការឈឺចាប់របស់បុរស[95] អាចត្រូវបានបកស្រាយថាជាលក្ខខណ្ឌតម្រូវសម្រាប់ភស្តុតាង*ផ្ទាល់* និងបញ្ជាក់ថា ទម្ងន់តិចតួច ឬគ្មាន ត្រូវបានផ្តល់ឲ្យចំពោះភស្តុតាង*ប្រយោល*។ លក្ខខណ្ឌតម្រូវបែបនេះ បានកំណត់បន្ទុកនៃការបង្ហាញភស្តុតាងខ្ពស់ហួសហេតុ។

33. ភស្តុតាងប្រយោលនៃការឈឺចាប់របស់បុរស និងផលប៉ះពាល់របស់វាដែលជាប់មកជាមួយដែលគាំទ្រនូវមូលដ្ឋានដែលបានបញ្ជាក់ពីលើកដំបូងរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីភស្តុតាងនៅក្នុងការវិភាគពីការឈឺចាប់របស់បុរស។ ការរកឃើញដែលថា "បុរសក៏មិនអាចបដិសេធការរួមសង្វាសក្នុងអាពាហ៍ពិពាហ៍បានឡើយ" គឺមិនត្រូវបានកំណត់អត្តសញ្ញាណជាក់លាក់នៅក្នុងការវិភាគអំពីការឈឺចាប់របស់បុរសបានទេ ក៏ប៉ុន្តែទំនងថា ការរកឃើញដែលត្រូវបានគាំទ្រដោយភស្តុតាងដែលបានលើកឡើងនៅក្នុងផ្នែកក្រោម ចំណងជើងថា "បរិយាកាសបង្ខិតបង្ខំ" និង "ការរួមដំណេកដោយបង្ខំរវាងប្តីប្រពន្ធ"[96]។ ផ្នែកទាំងពីរនេះនៃសាលក្រម បានពិភាក្សាពីភស្តុតាងដែលពួកកម្មាភិបាលបានតាមដានយ៉ាងដិតដល់ ថាតើការរួមសង្វាសត្រូវបានចប់សព្វគ្រប់ដែរ ឬទេ[97] ថាជីវិតប្តីប្រពន្ធត្រូវប្រថុយជីវិតពួកគេដោយការប្រឆាំងនឹង*អង្គការ* ដែរឬទេ[98] ថាតើមានលទ្ធភាពច្រើនប៉ុនណា ស្តីពីផលវិបាកអវិជ្ជមានចំពោះប្តីប្រពន្ធដែលបដិសេធមិនព្រមរួមសង្វាស[99] និងថាតើ "បុគ្គលទាំងនោះទទួលរង*ការភ័យខ្លាច* ដូច្នេះហើយ ទាំងបុរស និងនារីទាំងនោះ សុទ្ធតែមិនយល់ព្រមដោយពិតប្រាកដឡើយ"[100]។

---

[95] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ៣៧០១។

[96] ដូចបានពិភាក្សានៅក្នុង កំណត់សម្គាល់ជើងទំព័រលេខ ៨៩ *ខាងលើ*។

[97] ឯកសារ **E465** សាលក្រម សំណុំរឿង០០២/០២ កថាខណ្ឌ ៣៦៤៥-៣៦៤៦, ៣៦៥០, ៣៦៥៦-៣៦៥៧, ៣៦៦០-៣៦៦១។

[98] ឯកសារ **E465** សាលក្រម សំណុំរឿង០០២/០២ កថាខណ្ឌ ៣៦៤៦ (សក្ខីកម្មរបស់ ម៉ម សឿម) ៣៦៥៣, ៣៦៥៧។

[99] ឯកសារ **E465** សាលក្រម សំណុំរឿង០០២/០២ កថាខណ្ឌ ៣៦៤៥ (ត្រូវបានយកទៅមន្ទីរឃុំ) ៣៦៤៦ (ត្រូវបានយកទៅសម្លាប់ចោល ហៅយកទៅអប់រំឡើងវិញ ឬកសាងខ្លួន រំលោភដោយពួកកម្មាភិបាល) ៣៦៥០ (ត្រូវបានភ្ជង់កាំភ្លើងបង្ខំឲ្យ រួមភេទជាមួយប្តីរបស់ខ្លួន បន្ទាប់ពីពួកគេបានឮថាធ្វើហាក់ដូចជា "ត្រូវរ៉ូវជាមួយគ្នា") ៣៦៥១ (ត្រូវបានរំលោភដោយពួកកម្មាភិបាល) ៣៦៥៣ (ត្រូវបានគំរាមកំហែងថានឹងសម្លាប់) ៣៦៥៦-៣៦៥៧ (ត្រូវបានហៅប្រជុំដោយអាជ្ញាធរ ហើយគំរាម កំហែងដោយមានផលវិបាកផ្សេងៗ) ៣៦៥៨។

[100] ឯកសារ **E465** សាលក្រម សំណុំរឿង០០២/០២ កថាខណ្ឌ ៣៦៥៤ (សង្កត់ន័យបន្ថែម) *ដោយបានលើកឡើងពី* ឯកសារ **E1/472.1** Kasumi Nakagawa ប្រតិចារឹក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ទំព័រ៩០ ដែលនៅក្នុងនោះ Kasumi Nakagawa បានផ្តល់សក្ខីកម្មថា៖ "រីឯការរៀបការដោយបង្ខំ គឺមិនមានការយល់ព្រម គឺមិនដោយឆន្ទៈរបស់ភាគីមួយៗទេ។ សេចក្តីសម្រេច

34. រាល់ភ័ស្តុតាងទាំងអស់នេះ គឺចង្អុលបង្ហាញដោយប្រយោលពីការឈឺចាប់ខាងផ្លូវចិត្ត ដែលបុរសត្រូវទទួលរងនៅក្រោមលក្ខណ្ឌទាំងអស់នេះ ហើយអង្គជំនុំជម្រះនេះបានពឹងផ្អែកលើភ័ស្តុតាងប្រភេទនេះ ដើម្បីគាំទ្រដល់ការសន្និដ្ឋានរបស់ខ្លួន ដែលថាការរួមសង្វាសដោយបង្ខំ បានបណ្តាលឲ្យស្ត្រីរងនូវការឈឺចាប់យ៉ាងធ្ងន់ធ្ងរ[101]។ ប៉ុន្តែ មិនមានភ័ស្តុតាងណាមួយក្នុងចំណោមភ័ស្តុតាងទាំងនេះ ទំនងជាត្រូវបានថ្លឹងថ្លែងត្រឹមត្រូវដោយអង្គជំនុំជម្រះសាលាដំបូង នៅក្នុងការវិភាគពីការឈឺចាប់របស់បុរសនោះទេ ពីព្រោះអង្គជំនុំជម្រះកំពុងរកនូវភ័ស្តុតាង "ច្បាស់លាស់" គឺថាភ័ស្តុតាង*ផ្ទាល់*។ អង្គជំនុំជម្រះនេះមិនបានផ្តល់នូវការយល់ឃើញដោយមានសម្អាងហេតុចំពោះការប្រព្រឹត្តខុសគ្នាស្រឡះបែបនេះទេ។

35. អង្គជំនុំជម្រះសាលាដំបូង ក៏ខកខានមិនបានពិចារណាលើកំណត់ហេតុ និងរឿងរ៉ាវនៃការសិក្សាស្រាវជ្រាវដែលមាននៅក្នុងសំណុំរឿង ដែលបានរៀបរាប់ពីការកៀបសង្កត់ដែលបុរសទទួលរងក្នុងការរួមដំណេកអាពាហ៍ពាហ៍របស់ខ្លួន និងការភ័យខ្លាចរបស់ពួកគាត់ពីផលវិបាក ដែលពួកគាត់ត្រូវប្រឈម បើសិនជាពួកគាត់ខកខានមិនបានធ្វើដូច្នោះ[102]។ ការកៀបសង្កត់ និងការភ័យខ្លាចនេះ

ក្នុងការរួមដំណេក រួមរ័កហ្នឹង គឺថាមិនចេញពីឆន្ទៈរបស់គេទេ។ ពួកគេត្រូវបានបំភិតបំភ័យ ពួកគេមានការភ័យខ្លាច ទោះបីគេរួមដំណេកក៏ដោយ គឺមិនមែនជាការព្រមព្រៀងពិតចេញពីបុរស និងស្ត្រីទេ")។

[101] *សូមមើល* ឧទា. *ឯកសារ* **E465** *សាលក្រមសំណុំរឿង ០០២/០២* កថាខណ្ឌ៣៦៩០-៣៦៩៨។

[102] *សូមអាន ឧទា.* ឯកសារ **E3/9824** កំណត់ហេតុស្តាប់ចម្លើយ សុំ ប៉េត ឆ.៤១ ("ដើម្បីកុំឲ្យគេតាមដាន និងមានរឿងពួកយើង ក៏បានដេកនៅជាមួយគ្នា ជាប្តីប្រពន្ធនៅយប់នោះតែម្តង។ ម្យ៉ាងវិញទៀត ពួកយើងសុទ្ធតែដឹងថា នឹងមានរឿងអ្វីកើតឡើងចំពោះ អ្នកដែលអង្គការចាត់ទុកថា រស់នៅមិនចុះសម្រុងនឹងគ្នា")។ *កត់សម្គាល់* ថាភស្តុតាងរបស់ សុំ ប៉េត ត្រូវបានលើកឡើងតែម្តង គត់ នៅក្នុងឯកសារ **E465** សាលក្រម សំណុំរឿង០០២/០២ កំណត់សម្គាល់ជើងទំព័រលេខ ១២២៧៤ នៅក្នុងផ្នែក ១៤.៣.១២.១៖ ផលប៉ះពាល់នៃ "អាពាហ៍ពិពាហ៍ដោយបង្ខំ"។ ឯកសារ **E3/9822** កំណត់ហេតុស្តាប់ចម្លើយ វ៉ាត ផាត ឆ.៣៥៤, ៣៥៨ ("នីរសារកងវរៈជាអ្នកមកស៊ើបការថា អ្នកទាំងពីរហ្នឹងរៀបការចុះសម្រុងនឹងគ្នាដែរឬទេ ហើយពួកគេមកស៊ើប៣យប់។ [...] ខ្ញុំមានអារម្មណ៍ថាត្រូវគេបង្ខំដែរ ដូច្នេះខ្ញុំត្រូវរួមដំណេកជាមួយប្រពន្ធរបស់ខ្ញុំ")។ *កត់សម្គាល់* ថាភស្តុតាងរបស់ វ៉ាត ផាត ត្រូវបានលើកឡើងតែម្តង គត់ នៅក្នុងឯកសារ **E465** សាលក្រម សំណុំរឿង០០២/០២ កំណត់សម្គាល់ជើងទំព័រលេខ ១១៨៩២ នៅក្នុងផ្នែក ១៤.៣.១៖ សេចក្តីផ្តើម (ពាក់ព័ន្ធនឹងអង្គហេតុដែលការរៀបការបានចាប់ផ្តើមពី ខែមេសា ឆ្នាំ១៩៧៥)។ ឯកសារ **E3/9833** កំណត់ហេតុស្តាប់ចម្លើយ មូល អេង ឆ.២១២ ("យើងចាំបាច់ត្រូវតែរួមដំណេកជាមួយប្រពន្ធយើង ព្រោះគេនៅជិតហ្នឹងចាំមើលសភាពការក្រែងមិនស្រួល")។ *កត់សម្គាល់* ថាភស្តុតាងរបស់ មូល អេង ត្រូវបានលើកឡើងតែម្តងគត់ នៅក្នុងឯកសារ **E465** សាលក្រម សំណុំរឿង០០២/០២ កំណត់សម្គាល់ជើង ទំព័រលេខ ១២០៤៩ នៅក្នុងផ្នែក ១៤.៣.៥.៣៖ អាជ្ញាធរមានសមត្ថកិច្ច (ដោយពន្យល់ថា មេបញ្ជាការវរសេនាធំរបស់គាត់បានរៀបចំ និងធ្វើជាអធិបតីលើការរៀបការរបស់គាត់)។ ឯកសារ **E3/9662** កំណត់ហេតុស្តាប់ចម្លើយ កែវ ធារី ឆ.៤៤-៤៥ ("នៅពេលនោះ គាត់ដឹងថាខ្ញុំខ្លាច ប៉ុន្តែគាត់ត្រូវធ្វើតាមបញ្ជារបស់អង្គការ។ នៅសម័យនោះ យើងមិនខ្លាចឪពុកម្តាយទេ តែខ្លាចអង្គការ។ ស៖ តើអ្នកស្រីគិតថា បើអ្នកស្រីមិនដេកជាមួយប្តីអ្នកស្រី គេនឹងដឹងពីរឿងនេះឬ? ឆ.៤៥៖ ចាស យើងទាំងអស់គ្នាត្រូវគេតាមដានជារឿងរាល់ថ្ងៃ")។

ជាញឹកញាប់ បាននាំឲ្យបុរសបង្ខំប្រពន្ធរបស់ខ្លួនឲ្យរួមសង្វាស[103]។ អ្នកឆ្លើយជាបុរសម្នាក់នៅក្នុងការសិក្សារបស់អង្គការចិត្តសង្គមអន្តរវប្បធម៌ ("TPO") "ដូចខ្មោចប្រែរូប" បានប្រាប់អ្នកស្រាវជ្រាវថា បន្ទាប់ពីត្រូវបានព្រមានជាលើកទីពីរឲ្យ "គោរពតាមមាគ៌ារបស់*អង្គការ*" ទាក់ទងនឹង "ការស្រឡាញ់" ប្រពន្ធរបស់គាត់មក គាត់ក៏បាន ""ដេកជាមួយគ្នាត្រង់ៗ" ជាមួយប្រពន្ធរបសគាត់ឲ្យរួមភេទជាមួយគ្នាដើម្បី "រក្សាជីវិតរបស់ពួកគេ"" ទោះបីជា "ខ្ញុំមិនមានអារម្មណ៍ចង់រួមភេទជាមួយនាងក្តី ឬស្ទូម្បីតែទុកនាងជាប្រពន្ធរបស់ខ្ញុំ ព្រោះខ្ញុំមិនបានស្រឡាញ់នាងទាល់តែសោះ"[104]។ ជិត៤០ឆ្នាំក្រោយមក គាត់នៅតែរក្សាបទពិសោធន៍នេះនៅក្នុងខ្លួនរបស់គាត់ ថែមទាំងលាក់ពីកូនៗរបស់គាត់[105]។

---

*កត់សម្គាល់* ថាភស្តុតាងរបស់ កែវ ធារី មិនត្រូវបានលើកឡើងនៅក្នុងសាលក្រមទាល់តែសោះ។ ឯកសារ **E3/2959** Kasumi Nakagawa *អំពើហិង្សាលើយេនឌ័រក្នុងអំឡុងរបបខ្មែរក្រហម* ខែធ្នូ ឆ្នាំ២០០៨ KH 00738350 ("ខ្ញុំមានការភិតភ័យជាខ្លាំងហើយវាពិបាកខ្លាំងណាស់ ពីព្រោះយើងមិនធ្លាប់ស្គាល់គ្នា។ នៅព្រឹកបន្ទាប់ ប្តីរបស់ខ្ញុំនិយាយថាគាត់ខ្លាចអង្គការនឹងយកខ្ញុំទៅឆ្ងាយពីព្រោះខ្ញុំប្រកែកមិនព្រមដេកជាមួយគាត់ ... ខ្ញុំព្រួយបារម្ភ ប៉ុន្តែខ្ញុំមានអារម្មណ៍អាណិតប្តីរបស់ខ្ញុំពីព្រោះគាត់ស្លូត ដូច្នេះនៅពេលចុងក្រោយខ្ញុំក៏យល់ព្រម ... ខ្ញុំបានដេកជាមួយគាត់នៅយប់ទី៣)។ ឯកសារ **E3/9240** Rochelle Braaf *អំពើហិង្សាផ្លូវភេទលើជនជាតិភាគតិចក្នុងរបបខ្មែរក្រហម* ខែមីនា ឆ្នាំ២០១៤ EN 00992283 ("រឿងរ៉ាវរបស់បុរសម្នាក់ដូចទៅនេះ គឺស្តីពីគាត់ត្រូវបានគំរាមកំហែងពីព្រោះគាត់មិនរួមដំណេកនៅក្រោយអាពាហ៍ពិពាហ៍ដោយបង្ខំ គឺជាបទពិសោធន៍គំរូមួយរបស់អ្នកឆ្លើយតបៈ "ពួកឈ្លបលបមើលយើង។ បើយើងមិនរួមដំណេកទេ ព្រឹកស្អែកយើងនឹងត្រូវបានហៅទៅប្រជុំកសាងពាដង។ បើយើងមិនយល់ព្រមរួមដំណេក គេយកយើងទៅសម្លាប់ហើយ។ គូស្រករជាច្រើនត្រូវបានសម្លាប់ចោល..."។ ឯកសារ **E3/3416** Bridgette Toy-Cronin, *"ខ្ញុំចង់ប្រាប់អ្នក"៖ រឿងទាក់ទងនឹងការរំលោភបំពានផ្លូវភេទក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ* ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៨ KH 00721384 ("គូស្រករថ្មីថ្មោងតម្រូវឲ្យរួមរស់នៅជាមួយគ្នានៅរាត្រីដំបូង និងបីបួនរាត្រីបន្ទាប់មកទៀត។ ចំពោះគូស្រករណាដែលមិនធ្លាប់ស្គាល់គ្នាពីមុនមកទេ រាត្រីដំបូងនោះមានការលំបាកណាស់។ ស្ទើរតែអ្នកផ្តល់បទសម្ភាសន៍ទាំងអស់បានរាយការណ៍ថា ពួកគេជឿថា អង្គការតម្រូវថា គូស្រករថ្មីថ្មោងត្រូវតែរួមភេទគ្នា។ [...] សុផុន ដែលព្រមរៀបការនោះ បន្ទាប់ពីបានប្រកែកពីរដងនោះបាននិយាយថា ក្រោយពីរៀបការរួច "ពួកឈ្លបបានមកមើលថាតើ ពួកគេរួមភេទជាមួយគ្នាឬអត់ បើមិនរួមភេទគ្នាទេ ពួកគេនឹងយកយើងទៅកសាងមិនខាន។ ពួកយើងទាំងពីរនាក់ ក៏ព្រមរួមភេទជាមួយគ្នាដោយសារការខ្លាចអង្គការ""។

[103] ឯកសារ **E3/9614** Theresa De Langis និងគូកន កែប្រែខ្លួនប្រាណដូចខ្មោច៖ ការសិក្សាពីផលប៉ះពាល់នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងរបបខ្មែរក្រហម ឆ្នាំ២០១៤ EN 01037067។

[104] ឯកសារ **E3/9614** Theresa De Langis និងគូកន កែប្រែខ្លួនប្រាណដូចខ្មោច៖ ការសិក្សាពីផលប៉ះពាល់នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងរបបខ្មែរក្រហម ឆ្នាំ២០១៤ EN 01037067។

[105] ឯកសារ **E3/9614** Theresa De Langis និងគូកន កែប្រែខ្លួនប្រាណដូចខ្មោច៖ ការសិក្សាពីផលប៉ះពាល់នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងរបបខ្មែរក្រហម ឆ្នាំ២០១៤ EN 01037075។

36. ជួនកាល កម្មាភិបាលខ្មែរក្រហមបានបង្ខំឱ្យគូស្រករឱ្យរួមសង្វាស ក្រោមការគំរាមកំហែងប្រើហិង្សាដោយផ្ទាល់។ ដើមបណ្ដឹងរដ្ឋប្បវេណី មុំ វុន បានផ្ដល់សក្ខីកម្មអំពីបទពិសោធរបស់គាត់ នៅពេលដែលពួកឈ្លបបានភ្លង់កាំភ្លើងបង្ខំស្វាមីរបស់គាត់ឱ្យរំលោភសេពសន្ថវៈលើរូបគាត់៖

> ប៉ុន្តែគូភាគីប្ដីប្រពន្ធខ្ញុំទាំងពីរនេះ បាននិយាយថា យើងការៗសិនទៅ បើស្រុកស្រួលបួល ចាំយើងសុំបែកគ្នា។ និយាយអ៊ីចឹងទៅ អត់ដឹងថាឈ្លបគេនៅក្រោមផ្ទះទេ។ ដល់ឈ្លបគេឮសួរថាអ៊ីចឹង គេឡើងមកភ្លែត ស្រមកបីនាក់បណ្ដោយ។ ឡើងមកបីនាក់ហើយ គេថា មិនព្រមទៀត នៅចាំបែកគ្នាដល់ណាទៀត។ រួចមក គេយកកាំភ្លើងមកភ្លង់ ដោះអាវ ខាងប្រុសក៏ដោះអាវ ខាងស្រីក៏ដោះអាវឱ្យអស់ ដើម្បីរួមដំណេកជាមួយគ្នា។ គេកម្មាភិបាល គេឈ្លប គេមានពិល ដល់ហើយទាំងពីរនោះក៏ដោះអាវ ដោះខោទៅតាមគេ ចុះគេមានកាំភ្លើង យើងអត់ ទៅស៊ូនឹងម៉េចរួច។ ហើយដោះខោដោះអាវហើយ។ ដល់រួចហើយមិនព្រមនឹងដេកជុំគ្នាទេ។ ដល់រួចហើយ ដល់វាថាឱ្យឆាប់ដេកជាមួយគ្នា។ រួចហើយចាឆ្លុលពិល វាឆ្លុលពិល មើលយើងហើយ វាចាប់ប្រដាប់ប្រដាមនុស្សប្រុសដាក់មកជាមួយយើង។ [...] ដល់អាកាលណាវាបំណងវាបានធ្វើរួចសម្រេចហើយ វានិយាយថា "ទៅ! យើងទៅតាមអាខាងនោះទៀត អាខាងនេះវាចុយគ្នាបានហើយ យើងទៅខាងនោះទៀត"។ [...] ខ្លាចគេតែរហូតហ្នឹង។ របស់ងាប់ និងរបស់រស់សុខចិត្តនៅរស់ហើយ មិនឱ្យគេបាញ់ទេ សុខចិត្តទៅយ៉ាងណា ក៏យ៉ាងអ៊ីចុះទៅ ឱ្យតែវាបានរស់[106]។

37. ទោះជារឿងរ៉ាវរបស់ មុំ វុន ត្រូវបានផ្ដល់ពីខាងទស្សនៈស្ត្រីក៏ដោយ ក៏ស្វាមីរបស់គាត់ស្ថិតនៅក្រោមការប្រព្រឹត្តបែបបន្ទាបបន្ថោកដូចគាត់ដែរ និងស្ថិតក្រោមការកៀបសង្កត់ធ្ងន់ធ្ងរឱ្យរួមដំណេកនៅក្នុងអាពាហ៍ពិពាហ៍របស់ពួកគេ។ គាត់មិនត្រឹមតែត្រូវបានរំលោភលើរាងកាយប៉ុណ្ណោះទេ គាត់ថែមទាំងត្រូវបានរំពឹងផងដែរថា នឹងបានបំពេញនូវទង្វើខាងរាងកាយឱ្យបានសម្រេច ខណៈដែលការធ្វើមិនដឹងមិនឮអំពីការមិនស្ម័គ្រចិត្តរបស់ភរិយាគាត់ ក៏ដូចជាអារម្មណ៍បាក់ស្បាត ដែលគាត់អាចបានជួបប្រទះដោយផ្ទាល់។ ប៉ុន្តែ ទោះបីជាភ័ស្តុតាងស្ដីពីការរំលោភសេពសន្ថវៈរបស់ មុំ វុន ត្រូវបានយោងជាពិសេសនៅក្នុងសាលក្រម[107] អង្គជំនុំជម្រះសាលាដំបូង

[106] ឯកសារ **E1/475.1** មុំ វុន ប្រតិចារឹក ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង៖ 13.43.25-13.49.47។ អង្គជំនុំជម្រះពឹងផ្អែកលើភស្តុតាងរបស់ មុំ វុន នៅក្នុងឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៥០ និងកំណត់សម្គាល់ជើងទំព័រលេខ ១២២០៨-១២២១០ នៅក្នុងផ្នែក ១៤.៣.៨.៣ ការរួមដំណេកដោយបង្ខំរវាងប្ដីប្រពន្ធ។

[107] ឯកសារ **E465** សាលក្រម សំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៤២, ៣៦៤៨-៣៦៥០, ៣៦៥៨-៣៦៥៩ បាននាំឆ្ពោះទៅរកការរកឃើញនៅក្នុងកថាខណ្ឌ ៣៦៩៧-៣៦៩៨។

ខកខានមិនបានផ្តល់នូវការថ្លឹងថ្លែងសមស្របលើភ័ស្តុតាងអំពីការឈឺចាប់ ដែលស្វាមីរបស់គាត់ជួបប្រទះក្នុងកំឡុងពេលនៃអំពើដូចគ្នានេះទេ[108]។

38. ថ្វីបើព្យសនកម្មខ្លះដែលបណ្តាលមកពីការរួមភេទដោយបង្ខំ អាចជាបញ្ហាជាក់លាក់តាមលក្ខណៈភេទក្តី (ដូចជារហែក និងការចេញឈាមទ្វារមាស[109] ការមានគត៌[110] ជាដើម) គ្មានសច្ចធារណ៍ផ្លូវច្បាប់ថា បុរសបានទទួលរងនូវការឈឺចាប់តិចជាងស្ត្រីពីការរួមភេទដោយបង្ខំនោះទេ។ យ៉ាងណាមិញ មនោទស្សន៍យ៉េនឌ័រដែលបានកើតឡើងជាច្រើនសតវត្សរ៍មកហើយនោះ បានបង្កើតនូវផ្នត់គំនិតមួយថា បុរសតែងតែជាចារី និងមិនអាចជាជនរងគ្រោះនៃឧក្រិដ្ឋកម្មផ្លូវភេទបានទេ ដែលចំណុចនេះហើយ បានធ្វើឱ្យភាពជាជនរងគ្រោះផ្លូវភេទរបស់បុរស ពិបាកយល់[111]។ មនោទស្សន៍ដែលរួមចំណែកដល់ផ្នត់គំនិតនេះ រួមមាន (i) ជំនឿថា បុរសឱ្យតម្លៃ និងចូលចិត្តការរួមភេទ ដូច្នេះទស្សនៈនៃឱកាសរួមភេទជាមួយមនុស្សស្រី គឺវិជ្ជមាន[112]; (ii) ជំនឿថា បុរសមិនទទួលរងនូវ

---

[108] ឯកសារ **E465** សាលក្រម សំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧០១។

[109] *សូមមើល* ឯកសារ **E465** សាលក្រម សំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៩៧។

[110] ឯកសារ **E465** សាលក្រម សំណុំរឿង ០០២/០២ កថាខណ្ឌ ៣៦៨៥។

[111] ច្បាប់លំអៀងទៅរកយេនឌ័រជាញឹកញាប់តែងមានទស្សនទានថា បុរសគឺជាចារីនៃឧក្រិដ្ឋកម្មផ្លូវភេទ ហើយស្ត្រីគឺជាជនរងគ្រោះ បង្កើនបានជាសច្ចធារណ៍នៃការញែកដាច់ពីគ្នាខាងយេនឌ័ររវាងជនល្មើស និងជនរងគ្រោះ និងធ្វើឱ្យភាពរងគ្រោះខាងផ្លូវភេទរបស់បុរសពិបាកយល់(Fisher, N.L និង Pina, A.(២០១៣)។ "ទិដ្ឋភាពរួមមួយអំពីអក្សរកម្មស្តីពីភាពរងគ្រោះផ្លូវភេទរបស់បុរសពេញវ័យដែលត្រូវបានបញ្ចូលអង្គជាតិដោយស្ត្រី" *ការឈ្លានពាន និងឥរិយាបថហិង្សា,* 18(1), ទំព័រ ៥៤-៦១ ដែលអាចរកបានតាមគេហទំព័រ http://kar.kent.ac.uk/33378/, ត្រង់ ទំព័រ ៥, ១២ *យោង* Newburn, T. និង Stanko, E. (១៩៩៥), 'នៅពេលបុរសជាជនរងគ្រោះ៖ បរាជ័យនៃភាពរងគ្រោះសាស្ត្រ (The Failure of Victimology'), ទំព័រ ១៥៣-១៦៥ នៅក្នុង T. Newburn និង E. Stanko (eds), *មានតែបុរសធ្វើកិច្ចការនេះ៖ បុរស ភាពជាបុរស និងឧក្រិដ្ឋកម្ម,* London: Routledge. *សូមមើលផងដែរ* Rumney, P.N. និង Morgan-Taylor, M. (១៩៩៧), 'ការទទួលស្គាល់ជនរងគ្រោះបុរស៖ អព្យាក្រឹតភាពយេនឌ័រ និងច្បាប់ស្តីពីអំពើរំលោភសេពសន្ថវៈ៖ ភាគទី២, *ការពិនិត្យមើលច្បាប់អង់គ្លេ-អាមេរិកាំង លេខ២៦:* 330-356 ត្រង់ទំព័រ ៣៣០-៣៣២។ Muehlenhard, C.L. (១៩៩៨), 'សារសំខាន់ និងគ្រោះថ្នាក់នៃសិក្សាអំពីស្ត្រីព្រហើនខាងផ្លូវភេទ' នៅក្នុង Anderson, P.B និង Struckman-Johnson, C. (eds*), ស្ត្រីព្រហើនខាងផ្លូវភេទ: ទស្សនវិស័យ និងការខ្វែងយោបល់គ្នាបច្ចុប្បន្ន,* បោះពុម្ពលើកទី១, ញូវយ៉ក": សារព័ត៌មាន Guildford Press, 19-8 ត្រង់ទំព័រ ២៩ (កត់សំគាល់ថា មនោទស្សន៍យេនឌ័រ រួមបញ្ចូលទាំងមនោទស្សន៍ដែលថា បុរសជាអ្នកធ្វើឱ្យរងគ្រោះ ហើយស្ត្រីគឺជាជនរងគ្រោះ និងថា បុរសតែងតែស្វែងរកការរួមភេទ ហើយស្ត្រីប្រកែក ឬស្រុះស្រួលទៅតាមការចង់បានរបស់បុរស)។

[112] *សូមមើល ជាឧទាហរណ៍* Weare, S. . (២០១៧), ករណី "បង្ខំដើម្បីបញ្ចូលអង្គជាតិ៖ បទពិសោធរស់របស់បុរស", របបគំហើញនៃការស្រាវជ្រាវជាមូលដ្ឋាន, សាលាច្បាប់នៃសកលវិទ្យាល័យ Lancaster, ទំព័រ ១៣។ Weare, S. (២០១៨), 'អូ! អ្នកជាបុរស ហេតុអីបានជាត្រូវបានរំលោភដោយមនុស្សស្រីទៅវិញ ដូចជាគ្មានន័យសោះ៖ ចំពោះរឿងក្តីមួយសម្រាប់ការទទួលស្គាល់ និងការសំគាល់តាមផ្លូវច្បាប់នៃករណី "បង្ខំដើម្បីបញ្ចូលអង្គជាតិ" ជាអំពើរំលោភសេពសន្ថវៈ, *ទិនានុប្បវត្តិអន្តរជាតិនៃ*

ព្យសនកម្មផ្លូវអារម្មណ៍ពីបទពិសោធន៍នៃការរួមភេទប្រតិព័ទ្ធភេទផ្ទុយគ្នាទេ ទោះបីជាគ្មានការព្រមព្រៀងក៏ដោយ[113] និង (iii) ជំនឿថា តាមរាងកាយ បុរសមិនអាចនៅតែរក្សាប្រដាប់ភេទរបស់ខ្លួនឱ្យនៅរឹង និងអាចបញ្ចប់ការរួមភេទបានឡើយ ប្រសិនបើខ្លួនមានការភ័យខ្លាចពិតប្រាកដ ឬក៏អំពើនោះប្រឆាំងនឹងឆន្ទៈរបស់គាត់[114]។ មនោទស្សន៍ទាំងនេះ "កាត់បន្ថយភាពធ្ងន់ធ្ងរនៃអំពើរំលោភសេពសន្ថវៈចំពោះបុរស ឬអំពើបៀតបៀនផ្លូវភេទ និងបង្កើតឱ្យមានសច្ចធារណ៍មួយថា ឧប្បត្តិហេតុដូច្នេះមិនមែនជាបទល្មើស ពីព្រោះបុរសនឹងទទួលបាននូវភាពសប្បាយពីសកម្មភាពនេះ"[115]។

---

*ច្បាប់ក្នុងបរិបទ,* 14(1), ទំព័រ ១១០-១៣១ ត្រង់ទំព័រ១២២។ Fisher, N.L. និង Pina, A. (២០១៣), "ទិដ្ឋភាពរួមមួយអំពីអក្ខរកម្មស្តីពីភាពរងគ្រោះផ្លូវភេទរបស់បុរសពេញវ័យដែលត្រូវបានបញ្ចូលអង្គជាតដោយស្ត្រី" *ការឈ្លានពាន និងឥរិយាបថហិង្សា,* 18(1), ទំព័រ ៥៤-៦១ ដែលអាចរកបានតាមគេហទំព័រ http://kar.kent.ac.uk/33378/, ត្រង់ ទំព័រ ១៣-១៤។ Davies, M. និង Rogers, P(២០០៦),'ផ្គត់គំនិតអំពីជនរងគ្រោះជាបុរសក្នុងអំពើបៀតបៀនផ្លូវភេទដូចបានរៀបរាប់: ការពិនិត្យខាងផ្នែកអក្ខរកម្ម', *ការឈ្លានពាន និងឥរិយាបថហិង្សា,* ១១ (២០០៦) ៣៦៧-៣៧៧ ត្រង់ទំព័រ ៣៧២។

[113] Weare, S. (២០១៧), ករណី "បង្ខំដើម្បីបញ្ចូលអង្គជាតិ៖ បទពិសោធរស់របស់បុរស", របបគំហើញនៃការស្រាវជ្រាវជាមូលដ្ឋាន, សាលាច្បាប់នៃសកលវិទ្យាល័យ Lancaster, ទំព័រ១៣។ Weare, S. (២០១៨), 'អូ! អ្នកជាបុរស ហេតុអីបានជាត្រូវបានរំលោភដោយមនុស្សស្រីទៅវិញ ដូចជាគ្មានន័យសោះ៖ ចំពោះរឿងក្តីមួយសម្រាប់ការទទួលស្គាល់ និងការសំគាល់តាមផ្លូវច្បាប់នៃករណី "បង្ខំដើម្បីបញ្ចូលអង្គជាត" ជាអំពើរំលោភសេពសន្ថវៈ, *ទិនានុប្បវត្តិអន្តរជាតិនៃច្បាប់ក្នុងបរិបទ,* 14(1), ទំព័រ ១១០-១៣១ ត្រង់ទំព័រ១២៣។ Rumney, P.N. និង Morgan-Taylor, M. (១៩៩៧), 'ការទទួលស្គាល់ជនរងគ្រោះបុរស៖ អព្យាក្រឹតភាពយេនឌ័រ និងច្បាប់ស្តីពីអំពើរំលោភសេពសន្ថវៈ៖ ភាគទី២, *ការពិនិត្យមើលច្បាប់អង់ឡូ-អាមេរិកាំង លេខ២៦:* 330-356 ត្រង់ទំព័រ ៣៣៣-៣៣៤, ៣៣៩, ៣៤១។ Sarrel, P.M. និង Masters, W.H. (១៩៨២), 'ការរុកកួនផ្លូវភេទលើបុរសដោយនារី, *បណ្ណសារអំពីឥរិយាបថផ្លូវភេទ* ១១(២), ទំព័រ ១១៧-១៣១ ត្រង់ ១២៧ ("អារម្មណ៍ដែលមានជាទូទៅនៅក្នុងចំណោមបុរសគឺញាណមួយថា ពួកគេបានឆ្លើយតបខាងផ្លូវភេទនៅក្នុងកាលៈទេសៈផ្សេងៗ ដែលបុរសធម្មតាម្នាក់អាចនឹងមានអពលានុភាពនៃលិង្គ។ ជាលទ្ធផល ពួកគេបានចាត់ទុកខ្លួនឯងថា មិនធម្មតា"), ១៣០ ("ទោះបីជា [បុរស] អាចឆ្លើយតបខាងផ្លូវភេទត្រង់ពេលដល់ចំណុចលិង្គឡើងរឹង និងការបញ្ចេញទឹកកាមក្នុងពេលទទួលបទពិសោធន៍ដូច្នេះក្តី វាអាចមានដំណើរខុសប្រក្រតី ឬវិបល្លាសដែលជាសំណល់ពីការប៉ះទង្គិចយ៉ាងធ្ងន់ធ្ងរខាងផ្លូវភេទ")។

[114] *សូមមើលឧទាហរណ៍* Struckman-Johnson, C. និង Anderson, P.B (១៩៩៨) មានចំណងជើងថា '"Men Do and Women Don't": Difficulties in Researching Sexually Aggressive Women' នៅក្នុង Anderson, P.B និង Struckman-Johnson, C. (eds) Sexually aggressive women: Current perspectives and controversies, បោះពុម្ពលើកទី១ ទីក្រុងញូយ៉ក៖ រោងពុម្ព Guildford Press, ទំព័រ៩-១៨, ១១-១២។

[115] Fisher, N.L. និង Pina, A. (២០១៣), 'ការពិនិត្យមើលការបោះពុម្ពផ្សាយពីមុនៗអំពីបុរសរងគ្រោះដោយការរំលោភផ្លូវភេទដែលបានប្រព្រឹត្តឡើងដោយស្ត្រី (An overview of the literature on female-perpetrated adult male sexual victimization)' *ភាពឈ្លានពាន និងអាកប្បកិរិយាហិង្សា*, ១៨(១), ៥៤-៦១ នៅ http://kar.kent.ac.uk/33378/, ទំព័រ១៤។ *សូមមើលផងដែរ* ទំព័រ១៨ ("[…] ទាក់ទងនឹងការរួមភេទ មានបទដ្ឋានពីរ។ ស្ត្រីមិនត្រូវបានគេរំពឹងទុកថានឹងរួមភេទទេ លុះត្រាតែពួកគេស្ថិតក្នុងទំនាក់ទំនងស្នេហារឹងមាំ ខណៈដែលសម្រាប់បុរស ត្រូវបានគេគិតជាទូទៅថា ពួកគេនឹងរួមភេទទោះបីជាពួកគេ

មានប្រទេសជាច្រើនបានចាប់ផ្តើមទទួលស្គាល់អំពីការភាន់ច្រឡំនេះ ហើយបានដាក់ទៅក្នុងក្រមព្រហ្មទណ្ឌរបស់ពួកគេនូវបញ្ញត្តិជាបទព្រហ្មទណ្ឌចំពោះស្ថានភាពដែលចារី បង្ខំឱ្យជនរងគ្រោះប្រព្រឹត្តសកម្មភាពផ្លូវភេទណាមួយដែលប្រឆាំងនឹងឆន្ទៈរបស់គាត់ រួមទាំងការបញ្ចូលអង្គជាតិផងទាំងចំពោះចារី ឬជនទីបី[116]។ អំពើនេះគឺច្បាស់ណាស់ថា បានកើតឡើងនៅក្នុងសម័យកាលកម្ពុជាប្រជាធិបតេយ្យក្នុងបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ។

---

មិនស្ថិតក្នុងទំនាក់ទំនងស្នេហាក្តី។ ជាលទ្ធផល វាពិបាកក្នុងការជឿថា បុរសម្នាក់មិនបានផ្តើមគំនិតរួមភេទ ឬរីករាយក្នុងការរួមភេទដោយបង្ខំដែលធ្វើឡើងដោយស្ត្រី។")។ Sarrel, P.M. និង Masters, W.H. (១៩៨២), 'ការរំលោភផ្លូវភេទបុរសដោយស្ត្រី' *បណ្ណាសារនៃអាកប្បកិរិយាផ្លូវភេទ* ១១(២), ១១៧-១៣១ ត្រង់ទំព័រ១១៨ ("មានការរីករាលដាលនូវជំនឿថា វាស្ទើតែមិនអាចទៅរួចសម្រាប់បុរសម្នាក់ដើម្បីសម្រេចបាន ឬទប់មិនឱ្យចេញទឹកកាម នៅពេលដែលត្រូវបានគំរាម ឬត្រូវបានវាយប្រហារដោយស្ត្រី។ ការទទួលយកដ៏រីករាលដាលនៃជំនឿផ្លូវភេទនេះ មានការជំពាក់ទាក់ទងអកុសល្យសម្រាប់វេជ្ជសាស្ត្រចិត្តសាស្ត្រ និងច្បាប់។ ភាពបន្តកើតមានរបស់វានៅក្នុងវប្បធម៌របស់យើងបានកំណត់ន័យថា ជនរងគ្រោះជាបុរសនៃអំពើវាយប្រហារផ្លូវភេទមិនត្រូវបានកំណត់អត្តសញ្ញាណទេ និងថាភាពចាំបាច់នៃចិត្តតិកិច្ឆារបស់ពួកគេនៅតែមិនត្រូវបានបំពេញ។")។ Amrita Kapur និង Kelli Muddell, *នៅពេលដែលគ្មាននណាម្នាក់ហៅវាថាជាការរំលោភសេពសន្ថវៈ៖ ការដោះស្រាយអំពីអំពើហិង្សាផ្លូវភេទប្រឆាំងនឹងបុរស និងក្មេងប្រុសនៅក្នុងបរិបទអន្តរកាល* មជ្ឈមណ្ឌលអន្តរជាតិសម្រាប់យុត្តិធម៌អន្តរកាល ខែធ្នូ ឆ្នាំ ២០១៦ ទំព័រ១១-១២។

[116] *សូមមើល ឧទាហរណ៍* **<u>អាហ្វ្រិខាងត្បូង៖</u>** ច្បាប់ព្រហ្មទណ្ឌ (បទល្មើសផ្លូវភេទ និងបញ្ហាពាក់ព័ន្ធ) ច្បាប់វិសោធនកម្ម ៣២ នៃឆ្នាំ២០០៧ វិសោធនកម្ម ឆ្នាំ២០១៣ ទំពូក២ ចំណុច ១ ផ្នែកទី៤ ("ជនណាក៏ដោយ ('ក') ដែលបង្ខិតបង្ខំជនទីបី ដោយខុសច្បាប់ និងដោយមានចេតនា ('គ') ដោយគ្មានការយល់ព្រមពី គ ដើម្បីប្រព្រឹត្តអំពើរួមភេទដោយការដាក់បញ្ចូលអង្គជាតិជាមួយអ្នកជំទាស់តវ៉ា ('ខ') ដោយគ្មានការយល់ព្រមពី ខ នោះ ជននោះនឹងមានពិរុទ្ធចំពោះបទល្មើសនៃការរំលោភសេពសន្ថវៈដោយបង្ខំ។")។ **<u>ក្រូអាស៊ី៖</u>** ក្រមព្រហ្មទណ្ឌរបស់ប្រទេសក្រូអាស៊ីឆ្នាំ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១១ មាត្រា ១៥២-១៥៣ (ជារួមបទប្បញ្ញត្តិទាំងនេះកំណត់និយមន័យការរំលោភសេពសន្ថវៈថាជាការរួមបញ្ចូលបុគ្គលម្នាក់ផ្សេងទៀត តាមរយៈការបង្ខំ ឬការគំរាមកំហែងដោយការវាយប្រហារ ដើម្បីឱ្យចូលរួមដោយមិនមានការយល់ព្រមរបស់គាត់ក្នុងការរួមដំណេកជាមួយជនទីបី។)។ **<u>ណូវេ៖</u>** ក្រមព្រហ្មទណ្ឌស៊ីវិលទូទៅរបស់ប្រទេសណូវេ ថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩០២ វិសោធនកម្ម ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៥ ជំពូក ១៩ ផ្នែក១៩២ ("ជនណាដែល [...] គ) តាមមធ្យោបាយហិង្សា ឬការគំរាមកំហែង បង្ខំឱ្យជនណាម្នាក់ចូលរួមក្នុងសកម្មភាពផ្លូវភេទជាមួយជនម្នាក់ផ្សេងទៀត ឬដើម្បីប្រព្រឹត្តអំពើស្រដៀងគ្នានេះដោយខ្លួនឯងផ្ទាល់ គឺមានទោសពីបទរំលោភសេពសន្ថវៈ។")។ **<u>អូស្ត្រាលី (រដ្ឋវិកតូរីយ៉ា)៖</u>** ច្បាប់ព្រហ្មទណ្ឌអូស្ត្រាលីឆ្នាំ ១៩៥៨ វិសោធនកម្ម ថ្ងៃទី១ ខែមីនា ឆ្នាំ២០១៩ ផ្នែក ៣៩។ **<u>សឹង្ហបុរី៖</u>** ក្រមព្រហ្មទណ្ឌរបស់សាធារណរដ្ឋសិង្ហបុរី អនុម័ត១៨៧១ ធ្វើឡើងវិញ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៨ ជំពូក ២២៤ ផ្នែក ៣៧៦(២)។ **<u>ចក្រភពអង់គ្លេស (អាចអនុវត្តបានក្នុងប្រទេសអង់គ្លេស និងវែល)៖</u>** ច្បាប់ស្តីពីបទល្មើសផ្លូវភេទឆ្នាំ ២០០៣ ជំពូក ២ ភាគទី១ ផ្នែកទី៤។ **<u>អាល្លឺម៉ង់៖</u>** ក្រមព្រហ្មទណ្ឌអាល្លឺម៉ង់ ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨ វិសោធនកម្ម ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣ ផ្នែកទី១៧៧។ *សូមមើលផងដែរ* ក្រមព្រហ្មទណ្ឌជាច្រើនប្រើភាសាមិនច្បាស់ ដែលនឹងអនុញ្ញាតឱ្យមានការដាក់ទោសអ្នកណាម្នាក់ដែលបានបង្ខិតបង្ខំមនុស្សម្នាក់ផ្សេងទៀតឱ្យរួមភេទជាមួយជនទីបី ដោយការដាក់បញ្ចូលអង្គជាតិ៖ **<u>រុស្ស៊ី៖</u>** ក្រមព្រហ្មទណ្ឌរបស់សហព័ន្ធរុស្ស៊ី ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ ១៩៩៦ វិសោធនកម្ម ថ្ងៃទី១ ខែមីនា ឆ្នាំ២០១២ មាត្រា១៣៣ (ជាអំពើល្មើសច្បាប់ "ការបង្ខិតបង្ខំជនណាម្នាក់ឱ្យចូលរួមក្នុងអំពើខុសច្បាប់ ការរួមភេទរវាងមនុស្សប្រុសជាមួយក្មេងប្រុស

39. ការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង[117] រួមទាំង ការរកឃើញរបស់ខ្លួនដែលថា បុរស "មិនអាចបដិសេធមិនព្រមរួមសង្វាសក្នុងអាពាហ៍ពិពាហ៍"[118] គឺមានគ្រប់គ្រាន់ដើម្បីបង្ហាញអំពីកម្រិតនៃភាពធ្ងន់ធ្ងរនៃអំពើនេះ និងផលប៉ះពាល់របស់វាទៅលើបុរស។ នៅពេលដែលបន្ថែមទៅនឹងភ័ស្តុតាងផ្ទាល់ និងភ័ស្តុតាងប្រយោលជាច្រើន អំពីការឈឺចាប់របស់បុរស ដែលបានពិភាក្សានៅខាងលើនេះ ការលើកឡើងរបស់អង្គជំនុំជម្រះនេះ ដែលថា "អវត្តមាននៃភ័ស្តុតាងច្បាស់លាស់" ស្តីពីភាពធ្ងន់ធ្ងរនៃការទទួលរងនូវការឈឺចាប់របស់បុរស[119] គឺពិតជាមិនសមហេតុផលនោះទេ។ បើអង្គជំនុំជម្រះនេះបានពិចារណាឱ្យបានត្រឹមត្រូវនូវរាល់ភ័ស្តុតាងទាំងអស់ អង្គជំនុំជម្រះអាចសន្និដ្ឋានបានយ៉ាងសមហេតុសមផលថា បុរសដែលត្រូវបានបង្ខំឱ្យរួមដំណេកនៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ គឺបានទទួលរងការឈឺចាប់យ៉ាងធ្ងន់ធ្ងរ ដែលបង្កើតបានជាអំពើអមនុស្សធម៌ផ្សេងៗទៀត។ កំហុសរបស់អង្គជំនុំជម្រះនេះ ធ្វើឱ្យមោឃៈដល់សេចក្តីសម្រេចរបស់ខ្លួនដែលថា អំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈអំពើហិង្សាខាងផ្លូវភេទ មិនត្រូវបានបញ្ជាក់ភ័ស្តុតាង[120] ហើយបង្កើតបានជាភាពអយុត្តិធម៌។

## V. **សំណើសុំដំណោះស្រាយ**

40. សហព្រះរាជអាជ្ញាស្នើសុំអង្គជំនុំជម្រះតុលាការកំពូលឱ្យសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស នៅពេលដែលអង្គជំនុំជម្រះបានសន្និដ្ឋានថា បុរសដែលត្រូវបានបង្ខំឱ្យរួមដំណេកនៅ

---

ការរួមភេទរវាងស្ត្រីនិងស្ត្រីដូចគ្នា ឬការប្រព្រឹត្តសកម្មភាពផ្លូវភេទផ្សេងៗទៀតដោយមធ្យោបាយគំរាមរកប្រយោជន៍ ការគំរាមកំហែងអំពីការបំផ្លិចបំផ្លាញ ការធ្វើឱ្យខូចខាត ឬការដកហូតទ្រព្យសម្បត្តិ ឬដោយការប្រើប្រាស់សម្ភារៈ ឬជនក្រោមការគ្រប់គ្រងផ្សេងៗទៀតរបស់ជនរងគ្រោះ")។ **ដាណឺម៉ាក៖** ក្រមព្រហ្មទណ្ឌប្រទេសដាណឺម៉ាក ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ វិសោធនកម្ម ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៥ ជំពូក២៤ ផ្នែក២១៦ ("បទល្មើសផ្លូវភេទ៖ (១) ជនណាក៏ដោយដែលរួមដំណេកដោយបង្ខំ ដោយហិង្សា ឬតាមការគំរាមកំហែងប្រើហិង្សា ត្រូវមានទោសពីបទរំលោភសេពសន្ថវៈ")។ **សាធារណរដ្ឋឆែក៖** ក្រមព្រហ្មទណ្ឌរបស់សាធារណរដ្ឋឆែកឆ្នាំ ២០០៩ វិសោធនកម្ម ឆ្នាំ២០១១ ភាគ២ ជំពូក៣ ផ្នែក ១៨៥ ("ការរំលោភសេពសន្ថវៈ (១) ជនណាក៏ដោយដែលបង្ខំជនម្នាក់ផ្សេងទៀតឱ្យរួមដំណេកដោយហិង្សា ឬដោយការគំរាមប្រើហិង្សា ឬការគំរាមកំហែងអំពីភាពអន្តរាយធ្ងន់ធ្ងរផ្សេងៗទៀត")។ **ហ្វាំងឡង់៖** ក្រមព្រហ្មទណ្ឌរបស់ប្រទេសហ្វាំងឡង់ឆ្នាំ១៨៨៩ វិសោធនកម្មឆ្នាំ២០១៥ ជំពូក ២០ ផ្នែក១ ("ការរំលោភសេពសន្ថវៈ៖ ជនណាដែលបង្ខំជនម្នាក់ផ្សេងទៀតឱ្យរួមភេទដោយការប្រើ ឬការគំរាមប្រើហិង្សាសំដៅប្រឆាំងនឹងជននោះ ត្រូវកាត់ទោសចំពោះការរំលោភសេពសន្ថវៈ"។

[117] *សូមមើល* កថាខណ្ឌ ២៦ ខាងលើ។

[118] ឯកសារ **E465** សាលក្រម សំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧០១។

[119] ឯកសារ **E465** សាលក្រម សំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧០១។

[120] ឯកសារ **E465** សាលក្រម សំណុំរឿង ០០២/០២ កថាខណ្ឌ ៣៧០១។

ក្នុងអាពាហ៍ពិពាហ៍របស់ពួកគេ មិនមែនជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃអំពើអមនុស្សធម៌ផ្សេងៗទៀតទេនោះ។ សហព្រះរាជអាជ្ញាស្នើថា ការរកឃើញដោយមានកំហុសនេះ ទុកមួយអន្លើសិន ហើយការផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មនៃអំពើអមនុស្សធម៌ផ្សេងៗទៀតនេះ ត្រូវកែតម្រូវដោយរួមបញ្ចូលហិង្សាផ្លូវភេទលើជនរងគ្រោះជាបុរស ដើម្បីឲ្យជនរងគ្រោះទាំងបុរស និងទាំងស្ត្រីនៃអំពើបង្ខំឲ្យរួមដំណេកដូចគ្នានេះ ត្រូវបានទទួលស្គាល់យ៉ាងត្រឹមត្រូវ។ ការណ៍នេះ គឺត្រូវតាមវិធាន ១១០(៤) នៃវិធានផ្ទៃក្នុង ដូចដែល ខៀវ សំផន ត្រូវបានផ្តន្ទាទោសរួចហើយចំពោះឧក្រិដ្ឋកម្មនៃអំពើអមនុស្សធម៌ផ្សេងៗទៀត[121]៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញាជាតិ | ភ្នំពេញ | [signature] |
| | **លោក William SMITH**<br>សហព្រះរាជអាជ្ញាអន្តរជាតិរងជួស<br>**លោកស្រី Brenda J. HOLLIS**<br>សហព្រះរាជអាជ្ញាអន្តរជាតិ(បម្រុង) | | [signature] |

[121] ឯកសារ **E465** សាលក្រម សំណុំរឿង០០២/០២ កថាខណ្ឌ ៤១៩៨, ៤៣២៦-៤៣២៧។